ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាល

លេខ : ០៥ ខបក/អរប

នាយកដ្ឋានបណ្ដុះបណ្ដាល
ចូល
លេខ 166 ម៉ោង 9
ថ្ងៃទី 13 : 05 : 20
បញ្ជូន

ថ្ងៃសុក្រ ៦រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ,ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០

# របាយការណ៍
## ស្ដីពី
## សកម្មភាព និងលទ្ធផលការងារប្រចាំខែមេសា និងទិសដៅបន្ត សម្រាប់ខែឧសភា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានរដ្ឋបាល

ជ. ៤២០ [illegible] 15/05/2020

អគ្គនាយកដ្ឋានរដ្ឋបាល គឺជាអង្គភាពមួយក្នុងចំណោមអង្គភាពទាំង១១ ចំណុះក្រសួងមហាផ្ទៃ មានតួនាទីជាសេនាធិការឱ្យក្រសួង ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ ពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦ នៃរដ្ឋសភា ព្រមទាំងសម្របសម្រួលក្នុងការបង្កើត ការចុះបញ្ជី និងគ្រប់គ្រងសកម្មភាពសមាគម អង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយ។

ក្នុងខែមេសា ឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានអនុវត្តការងារតាមតួនាទី ភារកិច្ច ដោយសម្រេចលទ្ធផលបានដូចខាងក្រោម៖

### I-សកម្មភាពការងារ និងលទ្ធផល

#### ១-ការងារលិខិតស្នាម និងឯកសារផ្សេងៗ

-បានទទួលលិខិត និងឯកសារ ដែលបញ្ជូនមក ពីអគ្គលេខាធិការដ្ឋាន និងអង្គភាពនានាចំណុះ ក្រសួងមហាផ្ទៃសរុបចំនួន **៨៩៩ច្បាប់** និងបានធ្វើការបែងចែកជូនទៅនាយកដ្ឋានចំណុះរួមមាន៖ នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន **៣៤២ច្បាប់** នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន **៦៩ច្បាប់** នាយកដ្ឋានបុគ្គលិកចំនួន **២២៤ច្បាប់** នាយកដ្ឋានបណ្ដុះបណ្ដាលចំនួន **៣៨ច្បាប់** នាយកដ្ឋានមុខងារ និងធនធានចំនួន **២៣ច្បាប់** និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន **២០៣ច្បាប់**។

-បានទទួលលិខិតមកពីនាយកដ្ឋានជំនាញចំណុះអគ្គនាយកដ្ឋានរដ្ឋបាលមានចំនួន **៣៥៨ច្បាប់** ដែលក្នុងនោះមកពីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន **១០៧ច្បាប់** នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន **១៥ច្បាប់** នាយកដ្ឋានបុគ្គលិកចំនួន **១១២ច្បាប់** នាយកដ្ឋានបណ្ដុះបណ្ដាលចំនួន **២៣ច្បាប់** នាយកដ្ឋានមុខងារ និងធនធានចំនួន **២៤ច្បាប់** និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន **៧៧ច្បាប់** ដើម្បីដាក់ជូនអគ្គនាយកជ្រាបជារបាយការណ៍ និងពិនិត្យសម្រេច។

-បានចាត់ចែងបញ្ជូនឯកសារចំនួន **២៧៦ច្បាប់** ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងជ្រាបជារបាយការណ៍និងពិនិត្យ សម្រេច ដែលក្នុងនោះឯកសារមកពីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន **៨៦ច្បាប់** នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន **០៩ច្បាប់** នាយកដ្ឋានបុគ្គលិកចំនួន **៩៦ច្បាប់** នាយកដ្ឋានបណ្ដុះបណ្ដាលចំនួន **០៨ច្បាប់** នាយកដ្ឋានមុខងារ និងធនធានចំនួន **១៦ច្បាប់** និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន **៦១ច្បាប់**។

-បានទទួលឯកសារចំនួន **២១៤ច្បាប់** ដែលថ្នាក់ដឹកនាំក្រសួងមហាផ្ទៃពិនិត្យ សម្រេចរួច និងបញ្ជូនទៅនាយកដ្ឋានចំណុះ ដើម្បីចាត់ចែងបន្តរួមមានៈ នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន **៦៦ច្បាប់** នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន **០៧ច្បាប់** នាយកដ្ឋានបុគ្គលិកចំនួន **៧២ច្បាប់** នាយកដ្ឋានបណ្តុះបណ្តាលចំនួន **០៧ច្បាប់** នាយកដ្ឋានមុខងារ និងធនធានចំនួន **១៤ច្បាប់** និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៤៨ច្បាប់។

**២-ការងារចេញលិខិតបង្គាប់ការ និង លិខិតបញ្ជាបេសកកម្ម**

ក្នុងខែមេសា ឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានចេញលិខិតបង្គាប់ការ និងលិខិតបញ្ជាបេសកកម្មសរុបចំនួន **២៦ច្បាប់** ក្នុងនោះ លិខិតបង្គាប់ការចំនួន **១៣ច្បាប់** និងលិខិតបញ្ជាបេសកកម្មចំនួន **១៣ច្បាប់** ជូនថ្នាក់ដឹកនាំ និងមន្ត្រីចំណុះអគ្គនាយកដ្ឋានរដ្ឋបាល ដើម្បីចុះទៅបំពេញបេសកកម្មនៅតាមបណ្តាខេត្តនានា។

ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានរដ្ឋបាល ក៏បានចុះទិដ្ឋាការជូនមន្ត្រីរាជការមកពីបណ្តាខេត្តដែលមកបំពេញបេសកកម្មនៅក្រសួងមហាផ្ទៃផងដែរ។

**៣-ការងារប្រជុំ និងសិក្ខាសាលាផ្សេងៗ**

ក្នុងខែមេសា ឆ្នាំ២០២០នេះ **អគ្គនាយកដ្ឋានរដ្ឋបាល** បានរៀបចំកិច្ចប្រជុំ និងចាត់មន្ត្រីចូលរួមកិច្ចប្រជុំ សិក្ខាសាលា សន្និបាត វេទិកា និងកម្មវិធីនានាដូចខាងក្រោមៈ

-ចូលរួមក្នុងពិធីប្រគល់រថយន្តជូនស្នងការដ្ឋាននគរបាលខេត្ត និងពិធីប្រគល់ម៉ាស់ ឧបករណ៍ស្ទង់កំដៅ សាប៊ូ និងទឹកអាល់កុលដល់អគ្គនាយកដ្ឋានចំណុះក្រសួងមហាផ្ទៃក្រោមអធិបតីភាព**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**។

**▪ ការប្រជុំ សិក្ខាសាលាៈ**

-ដឹកនាំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-ដឹកនាំកិច្ចប្រជុំបែងចែកសម្ភារការពារ និងបង្ការជំងឺកូវីដ-១៩ ដែលជាអំណោយដ៏ថ្លៃថ្លារបស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការចំណុះអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

-ចូលរួមកិច្ចប្រជុំគណៈកម្មការអន្តរក្រសួង ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ (COVID-19) ក្រោមអធិបតីភាព **ឯកឧត្តម ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល នៅទីស្តីការក្រសួងមហាផ្ទៃ។

-ចូលរួមកិច្ចប្រជុំឆ្លងកម្មវិធីការងារឆ្នាំ២០២០ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ

-ចូលរួមកិច្ចប្រជុំឆ្លងផែនការសកម្មភាពឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍

-ចូលរួមកិច្ចប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយកាយអាវុធមហាប្រល័យ និងសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នៅទីស្តីការក្រសួងមហាផ្ទៃ

-ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីពិនិត្យលទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរយៈពេលខ្លីមធ្យម និងវែង របស់ពលករចំណាកស្រុកក្នុងស្ថានភាពរីករាលដាលនៃជំងឺកូវីដ-១៩

-ចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើកិច្ចការចាំបាច់មួយចំនួនរួមមានៈ ការពង្រឹងវេទនាសម្ព័ន្ធរបស់គ.ជ.អ.ប និងស្ថានភាពនៃការគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការអនុវត្តការងារតាមរចនាសម្ព័ន្ធថ្មី។

-ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់កម្រិតនយោបាយ រវាងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលជប៉ុនស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការនៅវិមានរដ្ឋាភិបាល(ទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)

-ចូលរួមកិច្ចប្រជុំពិភាក្សា លើសំណើសុំប្តូរទីតាំងមូលដ្ឋានកងរាជអាវុធហត្ថខណ្ឌដូនពេញ ទីតាំងប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ចតុមុខ និងទីតាំងបន្ទប់ទឹកសាធារណៈ ស្ថិតនៅសង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទៅកាន់ទីតាំងថ្មី និងស្នើសុំធ្វើប័ណ្ណកម្មសិទ្ធិនូវដីចំនួន៣ទីតាំងជូនលោកជំទាវឧកញ៉ា **ជឹង សុភាព** នៅ រដ្ឋបាលរាជធានីភ្នំពេញ

-ចូលរួមកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ស្តីពីការចុះពិនិត្យសិក្សា និងវាយតម្លៃលើករណីសំណើសុំជួលដីទំហំ ២២៣ហិកតា ២.៧៥១ម៉ែត្រការ៉េ ស្ថិតនៅឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដើម្បីបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ពាណិជ្ជកម្មពហុបំណងរបស់ក្រុមហ៊ុនអាណាចក្រឌីវេឡុបមែន គ្រុប នៅរដ្ឋបាលខេត្តកណ្តាល

-ចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីស្ថានភាពចំណូល និងការកែសម្រួលគម្រោងចំណាយថវិការាជធានី ខេត្ត ឆ្នាំ២០២០ ដែលរៀបចំដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

▪ **កម្មវិធីផ្សេងៗ៖**

-ចូលរួមជាមួយគណៈកម្មការអន្តរក្រសួងដើម្បីចុះត្រួតពិនិត្យជាក់ស្តែងអំពីវឌ្ឍនភាពនៃការងារសាងសង់ ច្រាំងទន្លេព្រែក ដើម្បីការពារបង្គោលព្រំដែនលេខ ២៤៥/៤ និង២៤៥/២(១)ក្នុងស្រុកកោះធំ ខេត្តកណ្តាល

-ចូលរួមពិធីប្រកាសចូលកាន់មុខតំណែងរបស់អភិបាលរង នៃគណៈអភិបាលខេត្តកំពង់ឆ្នាំង

-ចូលរួមជាសមាជិកក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពីការអនុវត្តអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀង ដែលពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថានតាមការស្នើសុំរបស់ក្រសួងបរិស្ថាន។

## ៤-ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត

### ៤.១-លិខិតបទដ្ឋានគតិយុត្តថ្នៃក្នុង

#### ៤.១.១-លិខិតបទដ្ឋានគតិយុត្តដែលសម្រេចបាន (គ្មាន)

#### ៤.១.២-លិខិតបទដ្ឋានគតិយុត្តដែលកំពុងរៀបចំ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះក្របខ័ណ្ឌមន្ត្រី ពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអង្គភាពចំណុះសាលាជាតិរដ្ឋបាលមូលដ្ឋាន និងឯកសារពាក់ព័ន្ធ

-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីគោលការណ៍ និងនីតិវិធីនៃការបង្កើត ការលុបចោលភូមិ ការកែសម្រួល និងការកំណត់ឈ្មោះរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ

-សេចក្តីព្រាងអនុក្រឹត្យថ្មីស្តីពីការគ្រប់គ្រងច្រកទ្វារព្រំដែននៅទូទាំងព្រះរាជាណាចក្រកម្ពុជា

-សេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តនៃគណកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីនីតិវិធីនៃការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី នីតិវិធី នៃការសុំច្បាប់ឈប់សម្រាករបស់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសេចក្តីណែនាំ ស្តីពីការវាយតម្លៃជ្រើសរើសការិយាល័យច្រកចេញចូលតែមួយដែលមានស្នាដៃល្អនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងគំរូកិច្ចសន្យា ស្តីពីការផ្តល់សេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ទីប្រជុំជនរបស់រដ្ឋបាលក្រុង ស្រុក

-សេចក្តីព្រាងសៀវភៅណែនាំស្តីពីកម្មវិធីពានរង្វាន់សម្រាប់ការអនុវត្តសេវាសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសៀវភៅណែនាំ ស្តីពី កិច្ចការរដ្ឋបាល សម្រាប់ប្រើប្រាស់នៅតាមអង្គភាពនានា(ផ្នែករដ្ឋបាលស៊ីវិល) ចំណុះទីស្តីការក្រសួងមហាផ្ទៃ។

### ៤.២-លិខិតបទដ្ឋានគតិយុត្តដែលសហការរៀបចំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ

#### ៤.២.១-លិខិតបទដ្ឋានគតិយុត្តដែលសម្រេចបាន

-ប្រកាសអន្តរក្រសួងលេខ ០២៧ស.អ.យ.ប្រ.ក ចុះថ្ងៃព្រហស្បតិ៍ ២រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ស្តីពីការការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ

-ប្រកាសអន្តរក្រសួងលេខ ១៥២ស.ន.ក ចុះថ្ងៃសុក្រ ៣កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសុខាភិបាលរាជធានី ខេត្ត។

#### ៤.២.២-លិខិតបទដ្ឋានគតិយុត្តកំពុងសហការរៀបចំ

-សេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ

-សេចក្តីព្រាងក្រមប្រតិបត្តិសម្រាប់អ្នករាជការសាធារណៈ

-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល

-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការកែសម្រួលអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

-សេចក្តីព្រាងរៀបចំកែសម្រួលប្រកាសអន្តរក្រសួងលេខ១៤៣៤២ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងរៀបចំកែសម្រួលប្រកាសអន្តរក្រសួងលេខ១៤៣៤៣ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួង ស្តីពីនីតិវិធី នៃការចុះបញ្ជីសិប្បកម្មដែលមានដើមទុនសមមូលលើសពី៨០លារៀលដល់២០០.០០០.០០០រៀល និងគ្មានហានិភ័យ

-សេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួង ស្តីពីការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងរៀបចំកែសម្រួលសេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០២០-២០៣០។

## ៥-ការងារបុគ្គលិក

### ៥.១-ការងារក្របខ័ណ្ឌ

គិតត្រឹមខែមេសា ឆ្នាំ២០២០ ស្ថានភាពក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃសរុបមានចំនួន **១៣៣៨០រូប/ស្រី៣៣៨៣រូប** (ក្នុងនោះក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិចំនួន **១.០០៦រូប/ស្រី២៤២រូប** ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្នាក់ក្រោមជាតិចំនួន **៩២៤៨រូប/ស្រី២៦៧៥រូប** ក្របខ័ណ្ឌមន្ត្រីពន្ធនាគារថ្នាក់ជាតិចំនួន **១.១៧៥រូប/ស្រី១៩០រូប** ក្របខ័ណ្ឌមន្ត្រីពន្ធនាគារថ្នាក់ក្រោមជាតិចំនួន **១.៩៥១រូប/ស្រី២៧៦រូប**) បើប្រៀបធៀបទៅនឹងខែមីនា ឆ្នាំ២០២០ ក្របខ័ណ្ឌថយចុះចំនួន **០១រូប**។ ជាមួយគ្នានេះដែរ ក្រសួងមហាផ្ទៃក៏បានបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលចំនួន **០៣រូប** ក្របខ័ណ្ឌចេញចំនួន **០៤រូប**(ក្នុងនោះផ្ទេរទៅក្នុងក្របខ័ណ្ឌក្រសួងនានាចំនួន **០២រូប** និងលុបឈ្មោះដោយមរណភាពចំនួន **០១រូប** លុបឈ្មោះដោយលាឈប់ពីការងារចំនួន **០១រូប**)។

### ៥.២-ការងារគោលនយោបាយមន្ត្រីរាជការស៊ីវិល

ក្នុងខែមេសា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានអនុញ្ញាតឱ្យមន្ត្រីរាជការឈប់សម្រាកពីការងារ និងស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សសរុបចំនួន០៤រូប/ស្រី០៣រូប(ក្នុងនោះសម្រាកលំហែមាតុភាពចំនួន០៣រូបនិងស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន០១រូប) និងអនុញ្ញាតឱ្យចូលបម្រើការងារក្នុងអង្គភាពដើមវិញចំនួន០២រូប។

**៥.៣-ការងារបុគ្គលិករដ្ឋបាលថ្នាក់ជាតិ**

ក្នុងខែមេសា ឆ្នាំ២០២០ ស្ថានភាពបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិលតាមមុខតំណែង ដែលកំពុងបម្រើការងារនៅគ្រប់អគ្គនាយកដ្ឋាន និងអង្គភាពចំណុះក្រសួងមហាផ្ទៃសរុបចំនួន **១.០០៦រូប/ស្រី ២៤២រូប ស្មើនឹង ២៤.០៥%** ដែលក្នុងនោះរួមមាន៖

-មន្ត្រីរាជការស៊ីវិលចំនួន **៩៨៧រូប/ស្រី ២៤១រូប ស្មើនឹង ២៤,៤១%** ក្នុងនោះរួមមាន (រដ្ឋលេខាធិការចំនួន **០៣រូប** អនុរដ្ឋលេខាធិការចំនួន **០៣រូប/ស្រី០១រូប** អគ្គនាយកចំនួន **០១រូប** អគ្គនាយករងចំនួន **២៧រូប/ស្រី០២រូប** អគ្គលេខាធិការរងចំនួន **០៤រូប/ស្រី០១រូប** គណៈកម្មាធិការ គ.ជ.ប.ទ ចំនួន **០៣រូប** (ក្នុងនោះសមាជិកគណៈកម្មាធិការចំនួន **០១រូប** ប្រធានលេខាធិការដ្ឋានចំនួន **០១រូប** អនុប្រធានលេខាធិការដ្ឋានចំនួន**០១រូប** ) ក្រុមប្រឹក្សានីតិកម្មចំនួន **០៧រូប/ ស្រី ០២រូប** (ក្នុងនោះប្រធានចំនួន **០១រូប** អនុប្រធានចំនួន **០៣រូប/ស្រី០១រូប** សមាជិកចំនួន **០៣រូប/ស្រី០១រូប**) លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) ចំនួន**១៧រូប/ស្រី០៦រូប** អគ្គាធិការចំនួន **០១រូប** អគ្គាធិការរងចំនួន **០៩រូប/ស្រី ០១រូប** ប្រធាននាយកដ្ឋានចំនួន **១២រូប/ស្រី០១រូប** អនុប្រធាននាយកដ្ឋានចំនួន **១៧១រូប/ស្រី២៥រូប** ប្រធានការិយាល័យចំនួន **៨៤រូប/ស្រី១៩រូប** អនុប្រធានការិយាល័យចំនួន**២៥១រូប/ស្រី ៧១រូប** និងមន្ត្រីចំនួន **៣៩៤រូប/ស្រី ១១៣រូប**។

-មន្ត្រីដែលផ្ទេរភារកិច្ចពីថ្នាក់ក្រោមជាតិមកទីស្តីការក្រសួងចំនួន **១៩រូប/ស្រី០២រូប ស្មើនឹង១០,៥២%**

-មន្ត្រីរាជការក្របខ័ណ្ឌដែលមានមុខតំណែងជាទីប្រឹក្សា និងជំនួយការចំនួន **៥៥៣រូប/ស្រី៥៦រូប** ស្មើនឹង **១០,១២%** ។ ដោយឡែកក្នុងខែ មេសា ឆ្នាំ២០២០នេះ រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ បានពិនិត្យ សម្រេចតែងតាំងមុខតំណែង ប្រគល់ភារកិច្ច ផ្លាស់ប្តូរកន្លែងធ្វើការជូនមន្ត្រីរាជការស៊ីវិល នៅថ្នាក់ជាតិសរុបចំនួន **១១រូប/ស្រី០២រូប**។

**៥.៤-ការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

គិតត្រឹមខែមេសា ឆ្នាំ២០២០ ស្ថានភាពបច្ចុប្បន្នភាពនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសមានដូចខាងក្រោម៖

-គណៈអភិបាលរាជធានី ខេត្តសរុបចំនួន**១៧៥រូប/ស្រី២៧រូប ស្មើនឹង១៥,៤២%** ក្នុងនោះ(អភិបាលរាជធានី ខេត្តចំនួន **២៥រូប/ស្រី០១រូប** អភិបាលរងរាជធានី ខេត្តចំនួន **១៥០រូប/ស្រី២៦រូប**)

-គណៈអភិបាលក្រុង ស្រុក ខណ្ឌសរុបចំនួន**៩៣៨រូប/ស្រី១៩៨រូប ស្មើនឹង២១.១១%** ក្នុងនោះ(អភិបាលក្រុង ស្រុក ខណ្ឌចំនួន **២០៣រូប/ស្រី០៧រូប** អភិបាលរងក្រុង ស្រុក ខណ្ឌចំនួន **៧៣៥រូប/ស្រី ១៩១រូប**)

-មន្ត្រីស្ថិតក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសរុបចំនួន **៦.៤៨៩រូប/ស្រី ២.១៥២រូប** ស្មើនឹង **៣៣.១៦%** ក្នុងនោះ (សាលារាជធានី ខេត្តចំនួន **២.៨០៩រូប/ស្រី៩១៥រូប** ស្មើនឹង **៣២.៥៧%** សាលាក្រុង ស្រុក ខណ្ឌសរុបចំនួន ៣.៦៨០រូប/ស្រី១.២៣៧រូប ស្មើនឹង ៣៣,៦១%) **ស្មៀនឃុំ សង្កាត់ចំនួន ១៦៤៦រូប/ស្រី ២៩៨រូប ស្មើនឹង ១៨.១% និងប្រធានទីស្នាក់ការច្រកទ្វារព្រំដែនចំនួន ៥៤រូប** ។ ទន្ទឹមនេះដែរ រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃក៏បានពិនិត្យសម្រេចតែងតាំងមុខតំណែង ប្រគល់ភារកិច្ចជូនអភិបាល អភិបាលរង នៃគណៈអភិបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ នាយករដ្ឋបាលសាលាខេត្ត ក្រុង ស្រុក ខណ្ឌ និងផ្លាស់ប្តូរភារកិច្ច និងតែងតាំងស្មៀនឃុំ សង្កាត់ចំនួន **១៧រូប/ស្រី០២រូប (ដូចក្នុងឧបសម្ព័ន្ធ១ក-១ឃ)**។

**៥.៥-ការងារក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

ស្ថានភាព បច្ចុប្បន្នភាពសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ទូទាំងប្រទេសមានដូចខាងក្រោម៖

-សមាសភាពក្រុមប្រឹក្សារាជធានី ខេត្តសរុបចំនួន **៥៥៩រូប/ស្រី៩៥រូប** (ស្មើនឹង ១៦,៩៩%) ក្នុងនោះ (ប្រធានក្រុមប្រឹក្សារាជធានី ខេត្តចំនួន **២៥រូប** សមាជិកក្រុមប្រឹក្សារាជធានី ខេត្តចំនួន **៥៣៤រូប/ស្រី ៩៤រូប**)។

-សមាសភាពក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌសរុបចំនួន ៣.៥៥៥រូប/ស្រី៦២១រូប (ស្មើនឹង១៧,៤៩%) ក្នុងនោះ ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន ២០៣រូប/ស្រី០៥រូប សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន ៣.៣៥២រូប/ស្រី៦១៦រូប។

-សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់សរុបចំនួន **១១.៩៧២រូប/ស្រី២.៣៨០រូប(ស្មើនឹង២០.៧៣%)**(ក្នុងនោះ មេឃុំចំនួន **១.៤០៥រូប/ស្រី ១១០រូប** ចៅសង្កាត់ចំនួន **២៤១រូប/ស្រី ២៦រូប** ជំទប់ទី១ ចំនួន **១.៤០៥រូប/ស្រី ២២៥រូប** ជំទប់ទី២ចំនួន ១.៤០៥ រូប/ស្រី៣០៧រូប ចៅសង្កាត់រងទី១ ចំនួន ២៤១រូប/ស្រី ៦២រូប ចៅសង្កាត់រងទី២ ចំនួន **២៤១រូប/ស្រី៥២រូប** និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន **៦.៦៣៨រូប/ស្រី១.៥៩៨រូប**)។ ក្នុងខែមេសា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានផ្លាស់ប្តូរ និងទទួលស្គាល់សមាសភាពក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ចំនួន **១៥រូប/ស្រី០២រូប (ដូចក្នុងឧបសម្ព័ន្ធ២ក)**ក្នុងនោះសមាសភាពសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន ០៣រូប/ស្រី០២រូប (**ដូចក្នុងឧបសម្ព័ន្ធ២ខ**) និងសមាសភាពសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ ចំនួន **១២រូប(ដូចក្នុងឧបសម្ព័ន្ធ២គ)**។

### ៥.៦-ការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល

ស្ថានភាពប្រវត្តិរូបមន្ត្រីរាជការស៊ីវិលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានបញ្ចូលក្នុងប្រព័ន្ធ ទិន្នន័យសរុបចំនួន **៩.៨៥៨រូប/ស្រី ២.៧៧៦រូប**(ក្នុងនោះមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិចំនួន **៨៨៨រូប/ស្រី ២០១រូប** និងមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិចំនួន **៨.៩៧០រូប/ស្រី២.៥៧៥រូប**)។

## ៦-ការងារអភិវឌ្ឍន៍សមត្ថភាព

### ៦.១-ការងារអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេស

ក្នុងខែមេសា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានចាត់មន្ត្រីចំនួន០៥រូបឱ្យចូលរួមវគ្គកម្មវិធីអភិវឌ្ឍន៍សមត្ថភាព គ្រូបង្គោលជំនាន់ទី២ ដែលរៀបចំដោយសាលាអភិបាលកិច្ចនៃក្រសួងមហាផ្ទៃសម្រាប់ឆ្នាំ២០២០។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានរដ្ឋបាលក៏បាននិងកំពុងចងក្រងទិន្នន័យអភិវឌ្ឍន៍សមត្ថភាព។

### ៦.២-ការងារអភិវឌ្ឍន៍សមត្ថភាពក្រៅប្រទេស និងលិខិតឆ្លងដែន

ក្នុងខែមេសា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានរៀបចំសំណើសុំចាត់បញ្ជូនមន្ត្រីផ្នែកទទួលពាក្យបណ្ដឹង និង អង្កេតស្រាវជ្រាវកិច្ចការរដ្ឋបាល នៃអគ្គាធិការដ្ឋាន ក្រសួងមហាផ្ទៃ ចំនួន **០១រូប** ឱ្យទៅសិក្សាថ្នាក់បរិញ្ញាបត្រ នៅប្រទេសអូស្ត្រាលី។

### ៦.៣-ការងារព័ត៌មាន និងផ្សព្វផ្សាយ

ចំពោះការងារព័ត៌មាន និងផ្សព្វផ្សាយ អគ្គនាយកដ្ឋានរដ្ឋបាល បាននិងកំពុងរៀបចំសេចក្តីព្រាងព្រឹត្តិបត្រ វិមជ្ឈការ និងវិសហមជ្ឈការលេខ០៤ និងបន្តធ្វើបច្ចុប្បន្នភាពគេហទំព័រអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ដោយបានបញ្ចូលអត្ថបទចំនួន **៥០ករណី** ព្រមទាំងបានបន្តរៀបចំចាត់ថែងចងក្រងឯកសារដើម្បីបង្ហោះក្នុង Telegram Channel របស់អគ្គនាយកដ្ឋានរដ្ឋបាល។

## ៧-ការងារគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ

### ៧.១-ការងារគាំទ្របច្ចេកទេស និងអន្តរាគមន៍

**ក្នុងកិច្ចគាំទ្របច្ចេកទេស និងអន្តរាគមន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរដ្ឋបាល បានរៀបចំ លិខិតក្នុងនាមក្រសួងមហាផ្ទៃជម្រាបជូនទៅរដ្ឋបាលរាជធានី ខេត្តដូចខាងក្រោម៖**

-រដ្ឋបាលខេត្តរតនគិរី ករណីឈ្មោះ **ទៀប ហ៊ិន, ឈា ច័ន្ទរិទ្ធី, វ៉ា សាលីម, ថាច់ ស៊ីផាន់, កើត ប៉ូលីន, ម៉ម យឿន** និងឈ្មោះ **ង៉ុយ ហាក់** ស្នើសុំចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង និងកំណត់ព្រំដីទំហំ ១១ហិកតា ស្ថិតនៅសង្កាត់កាចាញ ក្រុងបានលុង, ឃុំកាឡៃ ស្រុកអូរជុំ និងឃុំត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគិរី ដើម្បីចុះ បញ្ជីក្បាលដី ចេញប័ណ្ណកម្មសិទ្ធិ និងផ្លាស់ប្តូរប័ណ្ណកម្មសិទ្ធិជាថ្មី។

-រដ្ឋបាលខេត្តសៀមរាប ករណី៖

• ឈ្មោះ **កៃ ម៉ាឡា, ឃឹម ប៊ុនសុន, យុន ចិន្តា, ហែម សំបូរ, សាយ ម៉ុង, មៀន សេង, ម៉ៅ ចន្ធី, កួន អ៊ិន, អៀង ចិន្តា** និងឈ្មោះ **តាក់ សុផល** ស្នើសុំជួយអន្តរាគមន៍ ជួយពិនិត្យស្រាវជ្រាវ និងដោះស្រាយឡើងវិញលើភាព មិនប្រក្រតីក្នុងការច្រានចោលបណ្ដឹងទាមទារដីរបស់ពួកគាត់ ស្ថិតនៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប។

• ឈ្មោះ **នួន វីរៈ** និងឈ្មោះ **វណ្ណៈ ច័ន្ទតារាបុត្រ** ស្នើសុំអន្តរាគមន៍ឱ្យរដ្ឋបាលខេត្តសៀមរាប ចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង កំណត់ព្រំដី និងកាត់ឆ្វៀលដីទំហំ ១០៦ហិកតា ចេញពីតំបន់គម្របព្រៃឈើ ស្ថិតនៅភូមិទ័ពជ័យ ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប ដើម្បីចុះបញ្ជីក្បាលដី និងចេញប័ណ្ណកម្មសិទ្ធិ។

**-រដ្ឋបាលខេត្តកំពង់ស្ពឺ** ករណីៈ

• ឈ្មោះ **ហេង វណ្ណៈ** ស្នើសុំប្តឹងឈ្មោះ **ម៉ី ខេត** ជាមេឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និងបក្ខពួក លើករណីប្រើអំណាច ឃុបឃិតគ្នាលក់ដីរបស់គាត់ឱ្យអ្នកផ្សេងស្ថិតនៅភូមិរលួស ឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

• អំពីការចុះស្រាវជ្រាវករណីបណ្តឹងរបស់ឈ្មោះ **ឆាយ វិនិតា** ប្តឹងអាជ្ញាធរឃុំក្រាំងដីវាយ អាជ្ញាធរស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ឃុបឃិតគ្នាជាមួយឈ្មួញមានលុយមានអំណាច ឈូសឆាយយកដីកសិកម្មចំនួន ០២កន្លែង ស្ថិតនៅភូមិដក់ពរ ឃុំក្រាំងដីវាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

**-រដ្ឋបាលខេត្តកណ្តាល** ករណីឈ្មោះ **គួច យូផល** និងឈ្មោះ **អ៊ាវ ហ្គេច** ស្នើសុំពិនិត្យ និងដោះស្រាយជូនពួកគាត់អំពីករណីដែលអាជ្ញាធរភូមិ ឃុំ ស្រុក និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត មិនគោរពនិងអនុវត្តតាមស្មារតីលិខិតលេខ ១៨១៨ សជណ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ និងលិខិតលេខ ០២៦សជណ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០ របស់រដ្ឋបាលខេត្តកណ្តាលពាក់ព័ន្ធនឹងសំណើសុំចុះបញ្ជីក្បាលដីទំហំ ៨ម៉ែត្រx ៨៦៤ម៉ែត្រ ស្ថិតនៅភូមិស្វាយលាប ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល

**-រដ្ឋបាលខេត្តព្រះសីហនុ** ករណីៈ

• ឈ្មោះ **ហុក ឡេង** ស្នើសុំចាត់វិធានការលើជនខិលខូចឃុបឃិតគ្នាធ្វើប្លង់ និងរំលោភយកដីរបស់គាត់ចំនួន ០៤ទីតាំង ស្ថិតនៅសង្កាត់លេខ២ និងសង្កាត់លេខ៤ ក្រុងព្រះសីហនុ ឃុំរាម និងឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

• តំណាងប្រជាពលរដ្ឋ និងកងកម្លាំងប្រដាប់អាវុធរំសាយ ស្នើសុំចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង កំណត់ព្រំដី និងកាត់ឆ្វៀលដីទំហំ ៩១ហិកតា ៥៩អា ចេញពីដែនសមត្ថកិច្ចបរិស្ថាន ស្ថិតនៅភូមិចំណោតរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដើម្បីចុះបញ្ជីក្បាលដី និងចេញប័ណ្ណកម្មសិទ្ធិ

• ប្រជាពលរដ្ឋ ៦៤រូប ស្នើសុំចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង កំណត់ព្រំដី និងកាត់ឆ្វៀលដីទំហំ ១៥០ហិកតា ចេញពីដែនសមត្ថកិច្ចបរិស្ថាន ស្ថិតនៅសង្កាត់លេខ១ សង្កាត់លេខ៣ និងសង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដើម្បីចុះបញ្ជីក្បាលដី ចេញប័ណ្ណកម្មសិទ្ធិ និងផ្លាស់ប្តូរប័ណ្ណកម្មសិទ្ធិជាថ្មី។

• ឈ្មោះ **ស៊ិន ស៊ីធួន** ស្នើសុំចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង កំណត់ព្រំដី និងកាត់ឆ្វៀលដីទំហំ ៥ ហិកតា ២៦អា ស្ថិតនៅភូមិ០៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដើម្បីចុះបញ្ជីក្បាលដី ចេញប័ណ្ណកម្មសិទ្ធិ និងផ្លាស់ប្តូរប័ណ្ណកម្មសិទ្ធិជាថ្មី។

• តំណាងប្រជាពលរដ្ឋ ១៣៤គ្រួសារ ស្នើសុំមន្ត្រីរដ្ឋបាលខេត្តព្រះសីហនុ ជួយរកដំណោះស្រាយក្នុងការផ្តល់ដីថ្មីសម្រាប់រស់នៅ និងប្រកបមុខរបរដាំដុះចិញ្ចឹមជីវិតប្រចាំថ្ងៃ។

• តំណាងប្រជាពលរដ្ឋចំនួន ១៣០គ្រួសារស្នើសុំអន្តរាគមន៍ចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង កំណត់ព្រំដី និងកាត់ឆ្វៀលដីទំហំ ៣៧០ហិកតាចេញពីគម្របព្រៃឈើ និងដែនសមត្ថកិច្ចបរិស្ថាន ស្ថិតនៅភូមិពូធឿង ភូមិគគី និងភូមិចំណោទរាម ឃុំបិទត្រាង, ភូមិស្មាច់ដែង ភូមិរាម ភូមិអុង និងភូមិថ្មធំ ឃុំរាម,ភូមិស្រែចាមក្រោម ភូមិកោះខ្យង និងភូមិស្រែចាមលើ ឃុះអូរជ្រៅ,ភូមិអូរតាសេក និងភូមិអូរតាប៉ាង ឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដើម្បីចុះបញ្ជីក្បាលដី និងចេញប័ណ្ណកម្មសិទ្ធ និងផ្លាស់ប្តូរប័ណ្ណកម្មសិទ្ធសាជាថ្មី។

• ពលរដ្ឋចំនួន ៣៥រូប ស្នើសុំអន្តរាគមន៍ចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង កំណត់ព្រំដី និងកាត់ឆ្វៀលដីទំហំ ២២០ហិកតា ចេញពីតំបន់គម្របព្រៃឈើ ស្ថិតនៅភូមិទួលទទឹង២ និងភូមិទួលទទឹង៣ ឃុំទួលទទឹង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដើម្បីចុះបញ្ជីក្បាលដី និងចេញប័ណ្ណកម្មសិទ្ធិ។

-រដ្ឋបាលខេត្តបន្ទាយមានជ័យ ករណី៖

• ឈ្មោះ ប៉ូច ប៉េង ស្នើសុំជួយអន្តរាគមន៍ដោះស្រាយកេយុត្តិធម៌ ករណីទំនាស់ដីធ្លីទំហំ ៣៥ហិកតា មានទីតាំង នៅខាងជើងភូមិព្រៃសង្ការ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ និងសុំបដិសេធលិខិតលេខ១៧១/១៩ របក ចុះថ្ងៃ ទី៣០ ខែឧសភា ឆ្នាំ២០១៩ របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ

• ឈ្មោះសួន សេរីវឌ្ឍា ធ្វើសេចក្តីរាយការណ៍អំពីទំនាស់ដីធ្លីចំនួន ០៤ទីតាំង ស្ថិតនៅក្នុងខេត្តបន្ទាយមានជ័យ។

-រដ្ឋបាលខេត្តកំពត ករណី៖

• ឈ្មោះ ហុង សុមាលី ស្នើសុំធ្វើការអង្កេតស្រាវជ្រាវអំពីភាពស្របច្បាប់នៃការកាន់កាប់ដីមួយកន្លែងទំហំ ១៨ម៉ែត្រ x ៥០ម៉ែត្រ ស្ថិតនៅភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត។

• ឈ្មោះហ៊ិនចាន់ថុលប្តឹងឈ្មោះកែវប៊ុនធឿន,ញឹកសាមឿន,ភួតវង្សុល,សំ រ៉េន,ប៉ែននួន,ថាវសុវណ្ណរ៉េត (មេឃុំ),ទេពជុំ(មេភូមិ)និងបក្សពួកពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ និងរំលោភកាន់កាប់អចលនវត្ថុដោយហិង្សា

-រដ្ឋបាលរាជធានីភ្នំពេញ ករណីស្នើសុំស្លាកលេខរដ្ឋសម្រាប់ម៉ូតូម៉ាក Suzuki Smash 2019 ចំនួន ០៣ គ្រឿង ដោយចុះបញ្ជីសារពើភ័ណ្ឌជាទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលរាជធានីភ្នំពេញ

-រដ្ឋបាលខេត្តព្រះវិហារ ករណីស្នើសុំស្លាកលេខរថយន្ត ០១គ្រឿង របស់រដ្ឋបាលខេត្តព្រះវិហារ។

### ៧.២-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមានរាជធានីចំនួន ០១ ខេត្ត២៤ ក្រុង២៧ ស្រុក១៦២ ខណ្ឌ១៤ ឃុំ១.៤០៥ សង្កាត់២៤១ និងភូមិចំនួន ១៤.៣៨៤។

### ៧.៣-ការងារផ្តល់គោរមងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ

ក្រសួងមហាផ្ទៃ បានលើកសំណើជូនរាជរដ្ឋាភិបាលកម្ពុជា ករណីស្នើសុំគោរមងារជាឧកញ៉ា ចំនួន ០១រូប ស្នើសុំមេដាយព្រះរាជាណាចក្រកម្ពុជា ចំនួន ០៦គ្រឿង (ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០៣គ្រឿង ថ្នាក់មហាសេនាចំនួន ០១គ្រឿង ថ្នាក់ធិបឌិន្ទចំនួន ០១គ្រឿង និងថ្នាក់អស្សឫទ្ធិចំនួន ០១គ្រឿង) មេដាយមុនីសារាភ័ណ្ឌចំនួន ១៩គ្រឿង (ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០៦គ្រឿង ថ្នាក់មហាសេនាចំនួន ០៦គ្រឿង និងថ្នាក់ធិបឌិន្ទ ចំនួន ០៧គ្រឿង) មេដាយស្ថាបនាជាតិចំនួន១៤៩គ្រឿង (មេដាយមាសស្ថាបនាជាតិចំនួន ៩៦គ្រឿង មេដាយប្រាក់ស្ថាបនាជាតិចំនួន ៤១គ្រឿង និងមេដាយសំរិទ្ធិស្ថាបនាជាតិចំនួន ១២គ្រឿង) និងមេដាយសំរិទ្ធការងារចំនួន០២គ្រឿង ដើម្បីផ្តល់ជូនសប្បុរសជនដែលបានជួយកសាងសមិទ្ធផលជាច្រើននៅខេត្តកំពង់ចាម ស្វាយរៀង កំពត បន្ទាយមានជ័យ និងខេត្តស្ទឹងត្រែង ដោយចំណាយអស់ថវិកាសរុបចំនួន ៤.៧៥២.៤៧០ដុល្លារ(បួនលានប្រាំពីររយហាសិបពីរពាន់បួនរយចិតសិបដុល្លារសហរដ្ឋអាមេរិក) និងចំនួន ៨១.៤៤៧.០០០រៀល (ប៉ែតសិបមួយលានបួនរយសែសិបប្រាំពីរពាន់រៀលគត់) (ដូចក្នុងឧបសម្ព័ន្ធ៣)។

### ៧.៤-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា

#### ៧.៤.១-កម្មវិធីគាំទ្រដោយអង្គការសហប្រជាជាតិសម្រាប់កុមារ UNICEF

- តាមដាន និងត្រួតពិនិត្យការទូទាត់សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៩របស់រដ្ឋបាលរាជធានី ខេត្តគោលដៅ។

#### ៧.៤.២-គម្រោងសាងសង់អាគាររដ្ឋបាលស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ DCOCP

គិតត្រឹមខែមេសា ឆ្នាំ២០២០នេះ ការវិវឌ្ឍ នៃដំណើរការការដ្ឋានសាងសង់អគាររដ្ឋបាលស្រុក និងឃុំ សង្កាត់ គិតជារួមបានប្រមាណ៦៥% ។ ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាលក៏បានចាត់មន្ត្រី៖

-ចុះពិនិត្យតាមដានដំណើរការសាងសង់អគាររដ្ឋបាលសាលាស្រុកនិងអគាររដ្ឋបាលឃុំ សង្កាត់ដំណាក់កាលទី១ ទី២ និងទី៣ ។

-ចុះពិនិត្យការដ្ឋានសាងសង់អគាររដ្ឋបាលសាលាក្រុង ស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់មួយចំនួន ដែលបានបញ្ចប់ការសាងសង់ដើម្បីត្រៀមរៀបចំពិធីប្រគល់ទទួល។

### ៧.៥-ការងារគម្រោងមូលនិធិ និងការគាំទ្រក្រុង ស្រុក ឃុំ សង្កាត់

#### ៧.៥.១-គម្រោងក្រុង ស្រុក

ការរៀបចំគម្រោងក្រុង ស្រុក ឆ្នាំ២០២០ មានចំនួន **៣៥៧គម្រោង** ដែលក្នុងនោះ៖ គម្រោងមិនទាន់សិក្សាចំនួន **២២៨គម្រោង** (ស្មើនឹង៦៣,៨៧%) គម្រោងកំពុងដំណើរការសិក្សាចំនួន **៩២គម្រោង** (ស្មើនឹង២៥,៧៧%) និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន **៣៧គម្រោង** (ស្មើនឹង**១០,៣៦%**)។ សម្រាប់គម្រោងក្រុង ស្រុក ឆ្នាំ ២០១៩ មានចំនួន **៥៣៥គម្រោង** ដែលក្នុងនោះ៖ គម្រោងមិនទាន់សិក្សាចំនួន **៣០គម្រោង** (ស្មើនឹង៥,៦១%) គម្រោងកំពុងដំណើរការសិក្សាចំនួន **១២គម្រោង**( ស្មើនឹង ២,២៤%) និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន **៤៩៣គម្រោង** (ស្មើនឹង**៩២,១៥%**) ហើយបានដេញថ្លៃរួចចំនួន **៤៨៩គម្រោង**(ស្មើនឹង៩៨,១៩%)នៃគម្រោងដែលបានបញ្ចប់ការសិក្សា ។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងក្រុង ស្រុក ឆ្នាំ២០១៩ មានចំនួន **៤៨៨កិច្ចសន្យា** ក្នុងនោះរួមមាន៖ បញ្ចប់ការសាងសង់១០០% ចំនួន **៤៤៥កិច្ចសន្យា** (ស្មើនឹង**៩១.១៩%**) អនុវត្តបានលើស**៥០%** ចំនួន **២២កិច្ចសន្យា** (ស្មើនឹង**៤,៥១%**) អនុវត្តបានតិចជាង៥០%ចំនួន **១៤កិច្ចសន្យា** (ស្មើនឹង**២,៨៧%**) និងមិនទាន់បានអនុវត្តចំនួន **០៧កិច្ចសន្យា**(ស្មើនឹង **១,៤៣%**)។

#### ៧.៥.២-គម្រោងមូលនិធិឃុំ សង្កាត់

ការរៀបចំគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០២០ មានចំនួន **១.៧៨១គម្រោង**(ក្នុងនោះ កំពុងដំណើរការសិក្សាចំនួន **៨៧៨គម្រោង**(ស្មើនឹង៤៩,៣០%) មិនទាន់ចាប់ផ្តើមសិក្សាចំនួន **៥៣២គម្រោង**(ស្មើនឹង២៩,៨៧%) និងបានបញ្ចប់ការសិក្សាចំនួន **៣៧១គម្រោង**(ស្មើនឹង២០,៨៣%) ហើយគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន **២៩គម្រោង** (ស្មើនឹង៧,៨២%) បានដេញថ្លៃរួចរាល់ ។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិ ឃុំសង្កាត់ឆ្នាំ២០២០ សរុបចំនួន **២៤កិច្ចសន្យា** ក្នុងនោះ រួមមាន៖ ការអនុវត្តបានលើសពី៥០%ចំនួន **១កិច្ចសន្យា**(ស្មើនឹង៤,១៧%) ការអនុវត្តតិចជាង៥០%ចំនួន **០៨កិច្ចសន្យា**(ស្មើនឹង៣៣,៣៣%) និងមិនទាន់បានអនុវត្តចំនួន **១៥កិច្ចសន្យា**(ស្មើនឹង៦២,៥០%)។ ដោយឡែកការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៩ មានចំនួន **១.៨០៨គម្រោង**(ក្នុងនោះកំពុងសិក្សាចំនួន **០៩គម្រោង** (ស្មើនឹង០,៥០%) បានបញ្ចប់ការសិក្សាចំនួន **១៧៩៩គម្រោង** (ស្មើនឹង៩៩,៥០%) និងបានដេញថ្លៃរួចរាល់ចំនួន **១៧៨២គម្រោង**(ស្មើនឹង៩៩,០៦%)។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៩មានចំនួន **១.៧៧៥កិច្ចសន្យា** ក្នុងនោះរួមមាន៖ ការអនុវត្តបានលើសពី៥០%ចំនួន**២០៩កិច្ចសន្យា**(ស្មើនឹង១១,៧៧%) ការអនុវត្តបានតិចជាង៥០%ចំនួន**១៦០កិច្ចសន្យា** (ស្មើនឹង៩,០១%) បញ្ចប់ការសាងសង់១០០% ចំនួន **១.៣០៥កិច្ចសន្យា**(ស្មើនឹង ៧៣,៥២%) និងមិនទាន់បានអនុវត្តចំនួន**១០១កិច្ចសន្យា** (ស្មើនឹង ៥,៦៩%) ។

### ៧.៦-ការផ្តល់សេវា និងការដោះស្រាយវិវាទនៅមូលដ្ឋាន

#### ៧.៦.១-ការផ្ទេរមុខងារ និងធនធាន

-បានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារធនាគារពិភពលោក ស្តីពីផែនការសកម្មភាព ដែលត្រូវអនុវត្តបន្ទាប់ទៀតអំពីគម្រោងសាកល្បងការគ្រប់គ្រងសំរាមសំណល់រឹង និងសំណល់ផ្លាស្ទិក។

#### ៧.៦.២-ការផ្តល់សេវាតាមរយៈយន្តការច្រកចេញចូលតែមួយ

#### ក.ការផ្តល់សេវាតាមរយៈអង្គភាពច្រកចេញចូលតែមួយ

ក្នុងខែមេសា ឆ្នាំ២០២០នេះ អង្គភាពច្រកចេញចូលតែមួយទាំង២៥រាជធានី ខេត្តបានផ្តល់សេវារដ្ឋបាលសរុបចំនួន **៥២.៥៤៥សេវា** ក្នុងនោះបើប្រៀបធៀបចំនួនសេវាដែលបានផ្តល់នៅក្នុងចំណោមវិស័យទាំង១៤ ឃើញថាវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ផ្តល់សេវាបានច្រើនជាងគេគឺចំនួន ១៩.៨៨២សេវា(ស្មើនឹង៣៧,៨៤%)បន្ទាប់មកវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួន១០.៩០៦សេវា(ស្មើនឹង២០,៧៦%)

ចំពោះវិស័យហិរញ្ញវត្ថុ ... ចំណោមវិស័យទាំង១៤ ...

ចំពោះវិស័យហិស្តានទទួលបានសេវាតិចជាងគេគឺចំនួន ០៤សេវា (ស្មើនឹង០.០០៨%)(ដូចក្នុងឧបសម្ព័ន្ធ៤) ។ ជាមួយគ្នានេះដែរ អង្គភាពច្រកចេញចូលតែមួយទាំង ២៥រាជធានី ខេត្តទទួលបានចំណូលសរុបចំនួន ៦.៦៤២.១០៤.៨៩៤រៀល (ស្មើនឹង១.៦៦០.៥២៦,២២ដុល្លារអាមេរិក) ក្នុងនោះបើប្រៀបធៀបចំណូលដែលទទួលបាននៅក្នុងចំណោមវិស័យទាំង១៤ ឃើញថា វិស័យរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ទទួលបានចំណូលខ្ពស់ជាងគេគឺ **៤.៩៩៩.៦៥៦.០៩៤រៀល** (**ស្មើនឹង៧៥,២៧%**) បន្ទាប់មកវិស័យការងាររដ្ឋបាលទទួលបានចំណូលចំនួន **៥៥៥.៥៣២.៥០០រៀល**(ស្មើនឹង ៨,៣៦%) និងវិស័យហិស្តានទទួលបានចំណូលតិចជាងគេគឺចំនួន **១.០០០.០០០រៀល** (ស្មើនឹង០,០២%) (**ដូចក្នុងឧបសម្ព័ន្ធ៥**)។

ទន្ទឹមនេះ **អគ្គនាយកដ្ឋានរដ្ឋបាល**បានអនុវត្តសកម្មភាពមួយចំនួន ដើម្បីគាំទ្រដល់អង្គភាពច្រកចេញចូលតែមួយដូចខាងក្រោម៖

-បានពិនិត្យសេចក្តីព្រាងសេចក្តីណែនាំ និងទម្រង់បែបបទសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងវិស័យសាធារណការ និងដឹកជញ្ជូន

-បានរៀបចំកិច្ចប្រជុំក្រុមការងាររៀបចំប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់គ្រប់គ្រងការផ្តល់សេវាក្នុងអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-សហការជាមួយក្រសួងមុខងារសាធារណៈ ក្នុងការធ្វើបច្ចុប្បន្នភាពព័ត៌មានសេវាសម្រាប់គេហទំព័រច្រកទ្វារអេឡិចត្រូនិចផ្តល់ព័ត៌មានសេវាសាធារណៈ និងកម្មវិធីទូរស័ព្ទព័ត៌មានសេវាសាធារណៈ។

**ខ.ការផ្តល់សេវាតាមរយៈការិយាល័យច្រកចេញចូលតែមួយ**

ក្នុងខែមេសា ឆ្នាំ២០២០នេះ ការិយាល័យច្រកចេញចូលតែមួយទាំង៨៥គោលដៅបានផ្តល់សេវារដ្ឋបាលសរុបចំនួន **១៤៤.៩៧៣សេវា** បើប្រៀបធៀបចំនួនសេវាដែលបានផ្តល់នៅក្នុងចំណោមវិស័យទាំង១៤ ឃើញថាវិស័យនីត្យានុកូលកម្មបានផ្តល់សេវាបានច្រើនជាងគេគឺចំនួន **៨០.៩៨៥សេវា** (**ស្មើនឹង៥៥,៨៦%**) បន្ទាប់មកវិស័យអត្រានុកូលដ្ឋានចំនួន **៥២.០៦១សេវា** (**ស្មើនឹង៣៥,៩១%**) (**ដូចក្នុងឧបសម្ព័ន្ធ៦**)។ រយៈពេលដូចគ្នានេះដែរ ការិយាល័យច្រកចេញចូលតែមួយទាំង៨៥គោលដៅទទួលបានប្រាក់ចំណូលសរុបចំនួន**១.២៤៨.៥១០.០៤០ រៀល** (**ស្មើនឹង ៣១២.១២៧,៥១ ដុល្លារអាមេរិក**) បើប្រៀបធៀបចំណូលដែលទទួលបានពីវិស័យទាំង១៤ ឃើញថា វិស័យសុរិយោដីមានចំណូលខ្ពស់ជាងគេគឺចំនួន **៦៥៨.៧២៩.០០០រៀល** (**ស្មើនឹង៥២,៧៧%**) បន្ទាប់មកវិស័យសំណង់ទទួលបានចំណូលចំនួន **២៧៥.៥៩២.០០០រៀល** (**ស្មើនឹង៥២,៧៧%**)(**ដូចក្នុងឧបសម្ព័ន្ធ៧**)។

ទន្ទឹមនេះ **អគ្គនាយកដ្ឋានរដ្ឋបាល** បានអនុវត្តសកម្មភាពមួយចំនួនដើម្បីគាំទ្រដល់ការិយាល័យច្រកចេញចូលតែមួយដូចខាងក្រោម៖

-បានពិនិត្យសេចក្តីព្រាងសេចក្តីណែនាំ ស្តីពីនីតិវិធីនៃការគ្រប់គ្រង និងការផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងមុខងារវិស័យសាធារណការ និងដឹកជញ្ជូនផ្លូវគោក

-បានរៀបចំកិច្ចប្រជុំពិភាក្សា អំពីលទ្ធភាពនៃការរៀបចំផ្តល់សេវាអត្តសញ្ញាណកម្មតាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៧.៦.៣-ការដោះស្រាយវិវាទរដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

**ក).ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត**

ក្នុងខែមេសា ឆ្នាំ២០២០នេះ ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តបានទទួលបណ្តឹង សំណូមពរ ការទិតៀន ការសរសើរ និងការសាកសួរព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋដែលពាក់ព័ន្ធ និងមិនពាក់ព័ន្ធសរុបចំនួន **៥៧ករណី** ក្នុងនោះ បណ្តឹងក្នុងសមត្ថកិច្ចចំនួន **១១ករណី** (បញ្ចប់ការដោះស្រាយ **០២ករណី** កំពុងដោះស្រាយ **០៩ករណី**) បណ្តឹងក្រៅសមត្ថកិច្ចចំនួន **១៥ករណី** សំណូមពរចំនួន **១៥ករណី** ការសរសើរចំនួន **០១ករណី** និងការសាកសួរព័ត៌មាន

ផ្សេងៗចំនួន **១៥ករណី**។ ចំពោះបណ្តឹងក្នុងសមត្ថកិច្ចដែលនៅសល់ពីខែកន្លងមកមានចំនួន១៥ករណី (បញ្ចប់ការដោះស្រាយចំនួន ០៧ករណី កំពុងដោះស្រាយចំនួន ០៨ករណី)។

**ខ).ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ**

ក្នុងខែមេសា ឆ្នាំ២០២០នេះ ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌបានទទួលបណ្តឹង សំណូមពរ ការទិតៀនការសរសើរ និងការសាកសួរព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋដែលពាក់ព័ន្ធ និងមិនពាក់ព័ន្ធសរុបចំនួន **៧០៤ករណី** ក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ច **១៨ករណី** (បញ្ចប់ការដោះស្រាយ **១៧ករណី** កំពុងដោះស្រាយ **០១ករណី**)និងបណ្តឹងក្រៅសមត្ថកិច្ចចំនួន **១៩ករណី** ការសរសើរចំនួន **២២ករណី** សំណូមពរចំនួន **៥៦ករណី** ការសាកសួរព័ត៌មានផ្សេងៗចំនួន **៥៨៩ករណី**។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានរដ្ឋបាលក៏បានអនុវត្តកិច្ចការចាំបាច់មួយចំនួនដើម្បីគាំទ្រដល់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌដូចខាងក្រោម៖

-បានសហការរៀបចំសំណើសុំប្រកាសទទួលស្គាល់ប្រធានការិយាល័យប្រជាពលរដ្ឋក្រុងកោះរ៉ុង និងបានដាក់ចេញប្រកាសទទួលស្គាល់ប្រធានការិយាល័យប្រជាពលរដ្ឋក្រុងស្រុកចំនួន ០៧គោលដៅ រួមមាន៖ ស្រុកថាឡាបរិវ៉ាត់ ស្រុកឆ្លូង ស្រុកកោះញែក ស្រុកសន្ទុក ស្រុកគងពិសី ស្រុកកំពង់សីលា និងក្រុងតាខ្មៅ

-បានជួបប្រជុំជាមួយអង្គការតម្លាភាពកម្ពុជា ស្តីពីការរៀបចំកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងអង្គការតម្លាភាពកម្ពុជាជាមួយនាយកដ្ឋានមុខងារ និងធនធាន។

**៨-ការងារសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា**

ក្នុងខែមេសា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានផ្ញើលិខិតជម្រាបជូនទៅក្រសួង ស្ថាប័ន អង្គភាពនានាដូចខាងក្រោម៖

**-អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ** ស្តីពីរបាយការណ៍បំភ្លឺករណីឈ្មោះ **សួន វិច្ឆិកា** ផ្ញើសារចូលគេហទំព័រហ្វេសប៊ុក របស់សម្តេចក្រឡាហោម ពាក់ព័ន្ធនឹងរឿងស្មៀនឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ មិនធ្វើឯកសារជូនប្រជាពលរដ្ឋ

**-អគ្គនាយកដ្ឋានកស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ** ករណីរដ្ឋបាលខេត្តត្បូងឃ្មុំ ចាត់អភិបាលរងទទួលបន្ទុកការងារគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ តំណាងមន្ទីរ និងមន្ត្រីជំនាញពាក់ព័ន្ធចំនួន ១១រូប ដើម្បីចូលរួមក្នុងគណៈកម្មការអន្តរក្រសួងចុះពិនិត្យ សិក្សា និងវាយតម្លៃដីឯកជនរបស់រដ្ឋមួយកន្លែងមានទំហំ៨.៥២ម៉ែត្រការ៉េ ស្ថិតនៅភូមិទន្លេបិទលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដែលលោកឧកញ៉ា **អាន ម៉ានី** ស្នើសុំគោលការណ៍ទិញ

**-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ករណីស្នើសុំជួយអន្តរាគមន៍ទៅរដ្ឋបាលខេត្តកំពង់ធំ ករណីសកម្មភាពការឈូសឆាយព្រៃលិចទឹក នៅចំណុចក្រពើក្រមុំចំណុចដូនកាយ និងចំណុចក្បាលស្ទឹង ក្នុងឃុំចំណារក្រោម និងឃុំសំព្រាជ ស្រុកស្ទោង ខេត្តកំពង់ធំ។

**៩.ការងារតាមវិស័យផ្សេងៗ**

**៩.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន និងប័ណ្ណព្រំដែន**

**ក.ការងារច្រកទ្វារព្រំដែន**

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាមានច្រកទ្វារព្រំដែនសរុបចំនួន ៨២ច្រក រួមមាន ច្រកទ្វារកំពង់ផែអន្តរជាតិចំនួន ០៣ច្រក ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិចំនួន ០៣ច្រក ច្រកទ្វារព្រំដែនអន្តរជាតិចំនួន **២៦ច្រក** ច្រកទ្វារព្រំដែនទ្វេភាគីចំនួន **១៤ច្រក** ច្រកទ្វារតំបន់ព្រំដែនចំនួន **២៦ច្រក** និងច្រកទ្វារកំពង់ផែសមុទ្រចំនួន **១០ច្រក**។

**ខ.ការងារប័ណ្ណព្រំដែន**

គិតចាប់ពីថ្ងៃទី១៩ខែមីនា ដល់ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២០ អគ្គនាយកដ្ឋានរដ្ឋបាលបានផ្តល់ប័ណ្ណព្រំដែនជូនរដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃសរុបចំនួន ៨.០០០ប័ណ្ណ (ក្នុងនោះ ខេត្តបាត់ដំបង **៥.០០០ប័ណ្ណ** និង

ខេត្តប៉ៃលិន ៣.០០០ប័ណ្ណ) ។ ក្នុងខែមេសា ឆ្នាំ២០២០នេះ រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃបានផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋប្រើប្រាស់ជាផ្លូវការសរុបចំនួន**១.៥៨៥ប័ណ្ណ**(ក្នុងនោះខេត្តបាត់ដំបង**៧១៤ប័ណ្ណ** ខេត្តបន្ទាយមានជ័យ **៤៥១ប័ណ្ណ** ខេត្តឧត្តរមានជ័យ **១១៦ប័ណ្ណ** ខេត្តប៉ៃលិន **២៤៩ប័ណ្ណ** និងខេត្តកោះកុងចំនួន**៥៥ប័ណ្ណ**) និងរដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ បានផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋចំនួន **១១ប័ណ្ណ**។ ទន្ទឹមនេះ រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ បានធ្វើការបន្តសុពលភាពប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋ ដើម្បីចេញចូលឆ្លងកាត់ព្រំដែនកម្ពុជា-ថៃចំនួន **៦៤ប័ណ្ណ**។

***៩.២-ការងារចងសម្ព័ន្ធមេត្រីភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ***

**ដើម្បីបង្កើនទំនាក់ទំនង ចងសម្ព័ន្ធមេត្រីភាពជាមិត្តភាព និងសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានាជាមិត្ត ក្រសួងមហាផ្ទៃបានធ្វើលិខិតទៅប្រមុខរាជរដ្ឋាភិបាល និងស្ថាប័ននានា ៖**

-**សម្តេចតេជោនាយករដ្ឋមន្ត្រី** ករណីសភាពាណិជ្ជកម្មអឺរ៉ុបប្រចាំនៅកម្ពុជាស្នើសុំឱ្យមានការរក្សាខ្សែសង្វាក់ផ្គត់ផ្គង់ទំនិញ និងសេវាកម្មចាំបាច់ក្នុងករណីដែលប្រទេសត្រូវបានដាក់ឱ្យស្ថិតក្នុងភាពអាសន្ន

-ករណីស្ថានទូតហ្វីលីពីនប្រចាំកម្ពុជាស្នើសុំជួយសម្របសម្រួលការធ្វើដំណើររបស់ពលរដ្ឋខ្លួនពីបណ្តាខេត្តនានាមកកាន់រាជធានីភ្នំពេញ ដើម្បីធ្វើដំណើរមាតុភូមិនិវត្តន៍ទៅកាន់ប្រទេសហ្វីលីពីន។

***៩.៣-ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យ***

ក្នុងខែមេសា ឆ្នាំ២០២០នេះ **អគ្គនាយកដ្ឋានរដ្ឋបាល** បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេច លើសំណើសុំផ្តល់អនុលោមភាពគម្រោងអភិវឌ្ឍន៍ឆ្នាំ**២០២០** ចំនួន**៥គម្រោង**របស់រដ្ឋបាលខេត្តចំនួន ០៣ រួមមាន៖ ខេត្តស្វាយរៀង(**១គម្រោង**) ខេត្តព្រះសីហនុ(**៣គម្រោង**) និងខេត្តកំពង់ចាម(**១គម្រោង**) មានទឹកប្រាក់សរុបចំនួន **៩.៧៧៥.១០០.០០០រៀល (ប្រាំបួនប៊ីលានប្រាំពីររយចិតសិបប្រាំលានមួយរយពាន់រៀលគត់)** និងគម្រោងអភិវឌ្ឍន៍ឆ្នាំ២០១៩ចំនួន**០៦គម្រោង**របស់រដ្ឋបាលខេត្តកណ្តាលមានទឹកប្រាក់សរុបចំនួន **៣.២៣២.៨០៩.០០០រៀល(បីប៊ីលានពីររយសាមសិបពីរលានប្រាំបីរយប្រាំបួនពាន់រៀលគត់)** ។ ទន្ទឹមនោះដែរ ក្រសួងមហាផ្ទៃក៏បានសម្រេចផ្តល់អនុលោមភាពលើគម្រោងអភិវឌ្ឍឆ្នាំ**២០២០** ចំនួន**១៥គម្រោង** របស់រដ្ឋបាលខេត្តចំនួន**០៤**រួមមាន៖ ខេត្តព្រះសីហនុ(៧គម្រោង) ខេត្តកំពង់ចាម(៦គម្រោង) ខេត្តកណ្តាល(១គម្រោង) និងខេត្តស្វាយរៀង (១គម្រោង) មានទឹកប្រាក់សរុបចំនួន **១៦.៦២២.៣០៨.០០០រៀល (ដប់ប្រាំមួយប៊ីលានប្រាំមួយរយម្ភៃពីរលានបីរយប្រាំបីពាន់រៀលគត់)** និងគម្រោងអភិវឌ្ឍន៍ឆ្នាំ២០១៩ចំនួន **២៥គម្រោង**របស់រដ្ឋបាលរាជធានីខេត្តចំនួន**០៣**រួមមាន៖ រាជធានីភ្នំពេញ(១០គម្រោង) ខេត្តកណ្តាល(៨គម្រោង) និងរដ្ឋបាលខេត្តត្បូងឃ្មុំ(៧គម្រោង)មានទឹកប្រាក់សរុបចំនួន **២១៤.៧៤៤.១៩៥.០០០រៀល (ពីររយដប់បួនប៊ីលានប្រាំពីររយសែសិបបួនលានមួយរយកៅសិបប្រាំពាន់រៀលគត់)** ។ ទន្ទឹមនោះ **អគ្គនាយកដ្ឋានរដ្ឋបាល** ក៏បានរៀបចំលិខិតជម្រាបជូនទៅប្រមុខរាជរដ្ឋាភិបាល និងរដ្ឋបាលរាជធានី ខេត្តមួយចំនួនដូចខាងក្រោម៖

-**ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី** ករណីសំណើសុំទិញដីទំហំ **៧៨.៤០០**ម៉ែត្រការ៉េ ស្ថិតនៅភូមិក្បាលស្នួល ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ

-**រដ្ឋបាលរាជធានី ខេត្ត** ស្តីពីការពន្លឿនការរៀបចំកសាងផែនការអភិវឌ្ឍន៍រយៈពេល ប្រាំឆ្នាំកម្មវិធីវិនិយោគបីឆ្នាំរំកិល និងរៀបចំសំណុំឯកសារគម្រោងអភិវឌ្ឍន៍រាជធានី ខេត្ត ដើម្បីស្នើសុំផ្តល់អនុលោមភាពពីក្រសួងមហាផ្ទៃ និងប្រើប្រាស់ជាឯកសារមូលដ្ឋានក្នុងការរៀបចំកិច្ចលទ្ធកម្មសាធារណៈ

-បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំលើសំណើសុំផ្តល់អនុលោមភាពផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២០-២០២៤) របស់រដ្ឋបាលខេត្តកំពង់ចាម កំពង់ឆ្នាំង ពោធិ៍សាត់ ស្វាយរៀង និងខេត្តបាត់ដំបង ក្នុងនោះ ថ្នាក់ដឹកនាំបានសម្រេចផ្តល់អនុលោមភាពលើផែនការអភិវឌ្ឍន៍របស់រដ្ឋបាលខេត្តចំនួន១ គឺខេត្តកំពង់ចាម។

### ៩.៤-ការងារកិច្ចការសមាគម និងគណបក្សនយោបាយ

#### ៩.៤.១-ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

គិតមកដល់បច្ចុប្បន្នសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះឈ្មោះក្នុងបញ្ជី នៅក្រសួងមហាផ្ទៃ សរុបចំនួន **៥.៦៤៨**(ក្នុងនោះសមាគមចំនួន **២.៣០៦** អង្គការមិនមែនរដ្ឋាភិបាលចំនួន **៣.៣៤២**) និងសហគមន៍ជនជាតិដើមភាគតិចចំនួន**១៥៣**-(**ដូចក្នុងឧបសម្ព័ន្ធ១០**)។ ក្នុងខែមេសា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានសម្រេចចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន **២៣**(ក្នុងនោះសមាគម**១៥** អង្គការមិនមែនរដ្ឋាភិបាល **៨** និងសមាគមន៍ជនជាតិដើមភាគតិចចំនួន ១) ព្រមទាំងបានសម្រេចលុបឈ្មោះចេញពីបញ្ជីអង្គការមិនមែនរដ្ឋាភិបាល តាមការស្នើសុំសរុបចំនួន១ (**ដូចក្នុងឧបសម្ព័ន្ធ១០**) ។

ទន្ទឹមនេះ ក៏បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេចពាក់ព័ន្ធនឹងការងារនានា ដូចជាការសុំចុះឈ្មោះក្នុងបញ្ជីសមាគម អង្គការមិនមែនរដ្ឋាភិបាល ការសុំទទួលស្គាល់ប្រធាន ការសុំផ្លាស់ប្តូរសមាសភាពថ្មី នៃរចនាសម្ព័ន្ធ ការសុំធ្វើវិសោធនកម្មលក្ខន្តិកៈ ការសុំបើកទីស្នាក់ការសាខា ការសុំប្តូរឈ្មោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ការលុបឈ្មោះ ការផ្អាកសកម្មភាពបណ្តោះអាសន្នចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។ ជាមួយគ្នានេះផងដែរក៏បានរៀបចំរបាយការណ៍ផ្ញើជូនទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីត្រៀមចូលរួមក្នុងសម័យប្រជុំលើកទី៤៤ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវពាក់ព័ន្ធនឹងសិទ្ធិសេរីភាពក្នុងការជួបជុំដោយសន្តិវិធី និងសិទ្ធិក្នុងការបង្កើតសមាគម ។ លើសពីនេះក៏បានបញ្ចូលទិន្នន័យស្តេនសំណុំឯកសារពាក់ព័ន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន **៤០ច្បាប់** ក្នុងនោះសមាគមចំនួន **២០ច្បាប់** និងអង្គការមិនមែនរដ្ឋាភិបាលចំនួន **២០ច្បាប់**។

#### ៩.៤.២-ការងារគណបក្សនយោបាយ

គិតមកដល់បច្ចុប្បន្នគណបក្សនយោបាយមានចំនួនសរុប **៤៦គណបក្ស** ក្នុងនោះគណបក្សដែលបានចុះបញ្ជីមានចំនួន **៤៤**គណបក្ស និងគណបក្សដែលបានបង្កើតមានចំនួន **០២**គណបក្ស ។ ដោយឡែកនៅក្នុងខែមេសា ឆ្នាំ២០២០ ក្រសួងមហាផ្ទៃបានសម្រេចចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយចំនួន១(**ដូចក្នុងឧបសម្ព័ន្ធ១០**)។

## II-<u>បញ្ហាប្រឈម និងសំណូមពរ</u>

ទន្ទឹមនឹងការសម្រេចលទ្ធផលដូចខាងលើ ក្នុងការបំពេញភារកិច្ចកន្លងមក អគ្គនាយកដ្ឋានរដ្ឋបាលបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

-មិនទាន់បានដាក់ចេញគំរូពាក្យស្នើសុំ និងគំរូអាជ្ញាប័ណ្ណស្តង់ដាររួមសម្រាប់ការផ្តល់សេវារដ្ឋបាល នៅអង្គភាពច្រកចេញចូលតែមួយ

-ការធ្វើប្រតិភូកម្មមុខងារក្នុងវិស័យមួយចំនួនដល់ការិយាល័យច្រកចេញចូលតែមួយ នៅមានទំហំតូចមិនសក្តិសមនឹងស្ថានភាពបច្ចុប្បន្នរបស់ក្រុង ស្រុក ខណ្ឌ

-ទិន្នន័យផ្ទុកក្នុងប្រព័ន្ធ MIS កាន់តែច្រើនទៅៗធ្វើឱ្យប្រព័ន្ធ MIS ដំណើរការយឺតពិបាកក្នុងផលិតរបាយការណ៍ចេញ

-ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តមួយចំនួនពុំទាន់បានតែងតាំងបុគ្គលិកសម្រាប់បំពេញការងារ ឬសម្ភារពុំទាន់មានគ្រប់គ្រាន់ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តមួយចំនួនទៀតមានទីកន្លែងបំពេញការងារតូចចង្អៀតនៅឡើយ

-ការផ្គត់ផ្គង់សម្ភារការិយាល័យដូចជាក្រដាសទឹកថ្នាំ ម៉ាស៊ីនថតចម្លងដើម្បីឆ្លើយតបសំណូមពរការងារមិនទាន់បានគ្រប់គ្រាន់ហើយការបើកសម្ភារៈពុំសូវមានគុណភាព

-ការផ្គត់ផ្គង់ប្រេងឥន្ធនៈ និងប្រាក់បេសកកម្មសម្រាប់មន្ត្រីចុះបំពេញការងារនៅតាមខេត្ត មន្ត្រីរាជការត្រូវចំណាយថវិកាផ្ទាល់ខ្លួនជាមុនហើយបន្ទាប់ពីបញ្ចប់បេសកកម្មការបើកផ្តល់មានភាពយឺតយ៉ាវ

-មន្ត្រីមិនទាន់មានជំនាញគ្រប់គ្រាន់ក្នុងការសរសេរព័ត៌មាន និងការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាទាមទារត្រូវការបណ្តុះបណ្តាល

ដើម្បីជំរុញការអនុវត្តការងារឱ្យមានប្រសិទ្ធភាព ក៏ដូចជាការលើកទឹកចិត្តមន្ត្រី ក្នុងការបំពេញការងារ **អគ្គនាយកដ្ឋានរដ្ឋបាល** សំណូមពរដូចខាងក្រោម៖

-ពន្លឿនការកែសម្រួលទម្រង់បែបបទលក្ខខណ្ឌភ្ជាប់ការផ្តល់សេវាជាស្តង់ដារួម

-បង្កើនទំហំប្រតិភូកម្មលើប្រភេទសេវាដែលស្ថិតក្នុងសមត្ថកិច្ចក្រុង ស្រុក ខណ្ឌ

-ផ្គត់ផ្គង់សម្ភារការិយាល័យឱ្យបានសមស្រប និងទាន់ពេលវេលាដើម្បីជានាឆ្លើយតបសំណូមពរការងារ

-ផ្តល់ប្រេងឥន្ធនៈ និងប្រាក់បេសកកម្មឱ្យបានលឿនជាងមុនបន្តិចបន្ទាប់ពីចុះបំពេញបេសកកម្ម។

**III-ទិសដៅការងារបន្ត**

ដើម្បីជំរុញការអនុវត្តការងារឱ្យបានល្អប្រសើរ និងតាមផែនការដែលបានគ្រោងទុក អគ្គនាយកដ្ឋានរដ្ឋបាល បានដាក់ចេញនូវទិសដៅការងារបន្តសម្រាប់**ខែឧសភា**ឆ្នាំ២០២០ ដូចខាងក្រោម៖

**១-ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត**

**១.១-លិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុងដែលកំពុងរៀបចំ**

-សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអង្គភាពចំណុះសាលាជាតិរដ្ឋបាលមូលដ្ឋាន និងឯកសារពាក់ព័ន្ធ

-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីគោលការណ៍ និងនីតិវិធីនៃការបង្កើត ការលុបចោលភូមិ ការកែសម្រួល និងការកំណត់ឈ្មោះរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ

-សេចក្តីព្រាងអនុក្រឹត្យថ្មីស្តីពីការគ្រប់គ្រងច្រកទ្វារព្រំដែននៅទូទាំងព្រះរាជាណាចក្រកម្ពុជា

-សេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តនៃគណកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីនីតិវិធីនៃការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី នីតិវិធី នៃការសុំច្បាប់ឈប់សម្រាករបស់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសេចក្តីណែនាំ ស្តីពីការវាយតម្លៃជ្រើសរើសការិយាល័យច្រកចេញចូលតែមួយដែលមានស្នាដៃល្អនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងគំរូកិច្ចសន្យា ស្តីពីការផ្តល់សេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ទីប្រជុំជនរបស់រដ្ឋបាលក្រុង ស្រុក

-សេចក្តីព្រាងសៀវភៅណែនាំស្តីពីកម្មវិធីពានរង្វាន់សម្រាប់ការអនុវត្តសេវាសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសៀវភៅណែនាំ ស្តីពី "កិច្ចការរដ្ឋបាល" សម្រាប់ប្រើប្រាស់នៅតាមអង្គភាពនានា(ផ្នែករដ្ឋបាលស៊ីវិល) ចំណុះទីស្តីការក្រសួងមហាផ្ទៃ។

**១.២-លិខិតបទដ្ឋានគតិយុត្តដែលសហការរៀបចំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ**

-សេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ

-សេចក្តីព្រាងក្រមប្រតិបត្តិសម្រាប់អ្នករាជការសាធារណៈ

-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល

-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការកែសម្រួលអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

-សេចក្តីព្រាងរៀបចំកែសម្រួលប្រកាសអន្តរក្រសួងលេខ១៤៣៤២ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងរៀបចំកែសម្រួលប្រកាសអន្តរក្រសួងលេខ១៤៣៤៣ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួង ស្តីពីនីតិវិធី នៃការចុះបញ្ជីសិប្បកម្មដែលមានដើមទុនសមមូលលើសពី៨០លារៀលដល់២០០.០០០.០០០រៀល និងគ្មានហានិភ័យ

-សេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួង ស្តីពីការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងរៀបចំកែសម្រួលសេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០២០-២០៣០។

**២-ការងារបុគ្គលិក**

**២.១-ការងារក្របខ័ណ្ឌ**

-បន្តរៀបចំបែបបទប្រឡងជ្រើសរើស សិស្ស និស្សិតឱ្យចូលបម្រើការងារក្នុងក្របខណ្ឌមន្ត្រីរាជការមហាផ្ទៃក្នុងផែនការក្របខណ្ឌឆ្នាំ២០២០

-បន្តរៀបចំបែបបទសុំដំឡើងថ្នាក់ ឋានន្តរស័ក្តិប្រចាំឆ្នាំ និងតាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០២០

-បន្តរៀបចំបែបបទសុំដំឡើងឋានន្តរស័ក្តិ ជូនមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទស្នើសុំផ្ទេរក្របខ័ណ្ឌពីមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃទៅក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័នផ្សេងៗ និងពីក្របខ័ណ្ឌក្រសួង-ស្ថាប័នផ្សេងៗមកក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ដើម្បីទៅបំពេញការងារក្នុងមុខតំណែងថ្មីនិងអនុញ្ញាតឲ្យមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខ័ណ្ឌដើមវិញ

-បន្តរៀបចំបែបបទដើម្បីតាំងស៊ប់ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទ ដើម្បីសុំពិនិត្យនីត្យានុកូលភាពលើប្រកាសតែងតាំង និងប្រគល់ភារកិច្ច ដើម្បីស្នើសុំផ្តល់ប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទផ្តល់ទិដ្ឋាការលើសលាកបត្រជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ។

**២.២-ការងារគោលនយោបាយមន្ត្រីរាជការស៊ីវិល**

-បន្តរៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីរាជការដែលទទួលមរណភាពនិងមន្ត្រីរាជការដែលសុំលាឈប់ពីការងារ

-បន្តរៀបចំការផ្តល់ប័ណ្ណសម្គាល់ខ្លួនជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមការស្នើសុំ

-បន្តរៀបចំសំណុំលិខិតអនុញ្ញាត ឱ្យមន្ត្រីរាជការចូលបម្រើការងារនៅអង្គភាពដើមវិញ បន្ទាប់ពីសុំស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមការស្នើសុំ ។

-បន្តរៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីដែលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយហួសកាលកំណត់
-បន្តរៀបចំសំណុំលិខិតអនុញ្ញាតឈប់សម្រាកលំហែមាតុភាព
-បន្តរៀបចំសំណុំបែបបទផ្ទេរកូនកំព្រា និងសុំប្រាក់ជានាវាប់រងសង្គម
-បន្តពិនិត្យផ្ទៀងផ្ទាត់សលាកបត្រមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារដែលដល់អាយុត្រូវចូលនិវត្តន៍ ឆ្នាំ២០២០
-បន្តពិនិត្យផ្ទៀងផ្ទាត់ការស្នើសុំគ្រឿងឥស្សរិយយសមេដាយការងារ និងប័ណ្ណសរសើ ជូនមន្ត្រីរាជការស៊ីវិល។

**២.៣-ការងារបុគ្គលិករដ្ឋបាលថ្នាក់ជាតិ**

-បន្តរៀបចំផ្លាស់ប្តូរកន្លែងធ្វើការ រៀបចំដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិរយៈពេល០៣ខែ សម្រាប់មន្ត្រីរាជការស៊ីវិល និងដាក់ទណ្ឌកម្មខាងវិន័យសម្រាប់មន្ត្រីពន្ធនាគារ
-បន្តរៀបចំធ្វើបញ្ជីបច្ចុប្បន្នភាពសម្រាប់ខែបន្ទាប់របស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
-បន្តរៀបចំធ្វើបញ្ជីបច្ចុប្បន្នភាព និងតែងតាំងទីប្រឹក្សា ជំនួយការក្រសួងមហាផ្ទៃ និងទីប្រឹក្សា ជំនួយការ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរៀបចំស្នើសុំប្រាក់បៀវត្សទីប្រឹក្សា ជំនួយការ
-បន្តរៀបចំការតែងតាំង ផ្ទេរ និងប្រគល់ភារកិច្ចមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ
-បន្តរៀបចំការផ្លាស់ប្តូរកន្លែងធ្វើការងាររបស់មន្ត្រីរាជការស៊ីវិល
-បន្តរៀបចំក្រុមការងារពិពណ៌នាមុខតំណែងមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ
-បន្តរៀបចំការផ្អាកការងារដោយផ្អាកបៀវត្ស។

**២.៤-ការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តចូលរួមសហការជាមួយអង្គភាពពាក់ព័ន្ធ ក្នុងការចុះពង្រឹងរបៀបរបបការងារ និងការគ្រប់គ្រងមន្ត្រីរាជការ នៅតាមសាលារាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
-ពិនិត្យ និងសិក្សាលើសំណើសុំកែសម្រួលរចនាសម្ព័ន្ធទីចាត់ការ អង្គភាព និងការិយាល័យនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ
-បន្តពិនិត្យ និងលើកយោបល់ ដើម្បីស្នើសុំការសម្រេចលើការតែងតាំងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវដល់អាណត្តិ ០៤ឆ្នាំ( និង០៨ឆ្នាំ )របស់ខ្លួន
-បន្តធ្វើបច្ចុប្បន្នភាពបញ្ជីគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
-បន្តសហការ និងសម្របសម្រួលជាមួយនឹងអង្គភាពប្រឆាំងអំពើពុករលួយលើការងារប្រកាសទ្រព្យសម្បត្តិ និងបំណុលសម្រាប់ឆ្នាំ២០២០។

**២.៥-ការងារក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តយកចិត្តទុកដាក់ពិនិត្យលើកយោបល់ទាក់ទងការផ្លាស់ប្តូរ និងទទួលស្គាល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ឱ្យបានទាន់ពេលវេលា
-បន្តធ្វើបច្ចុប្បន្នភាពបញ្ជីក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

**២.៦-ការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល**

-សិក្សា និងរៀបចំភ្ជាប់ប្រព័ន្ធគ្រប់គ្រងទិន្នន័យគ្រប់ការិយាល័យដែលពាក់ព័ន្ធចំណុះនាយកដ្ឋានបុគ្គលិក
-បន្តសហការជាមួយក្រុមហ៊ុនក្នុងការរៀបចំប្រព័ន្ធឲ្យមានភាពល្អប្រសើរជាងមុន
-បន្តធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិល ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាបន្តបន្ទាប់
-បន្តសហការណ៍ជាមួយការិយាល័យជំនាញពាក់ព័ន្ធដើម្បីធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការដូចជាៈការផ្លាស់ប្តូរកន្លែងធ្វើការ ការតែងតាំង ការប្រែប្រួលថ្នាក់ ឋានន្តរស័ក្តិ ការលុបឈ្មោះ ការចូលនិវត្តន៍...។ល។

**៣-ការងារអភិវឌ្ឍន៍សមត្ថភាព**

**៣.១-ការងារអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេស**

-ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់រាជធានី ខេត្ត ស្របតាមផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ ស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តចងក្រងទិន្នន័យអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ

-រៀបចំកិច្ចការចាំបាច់នានាសម្រាប់ដាក់ឱ្យដំណើរការសាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA)

-ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌដូចខាងក្រោម៖

*វគ្គបណ្តុះបណ្តាលតម្រង់ទិស

*វគ្គជំនាញរដ្ឋបាល

*វគ្គជំនាញគ្រប់គ្រងបុគ្គលិក

*វគ្គជំនាញគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

*វគ្គជំនាញកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ

*វគ្គបណ្តុះបណ្តាលអំពីការងារអប់រំ

*វគ្គបណ្តុះបណ្តាលអំពីការងារសុខាភិបាល

*វគ្គភាពជាអ្នកដឹកនាំសម្រាប់អភិបាល/ប្រធានក្រុមប្រឹក្សា

*វគ្គបណ្តុះបណ្តាលអំពីគោលការណ៍ បែបបទ នីតិវិធី និងស្តង់ដាផ្តល់សេវាតាមវិស័យ

-សិក្សាស្រាវជ្រាវ និងចងក្រងឯកសារអភិបាលកិច្ចមូលដ្ឋាន។

**៣.២-ការងារអភិវឌ្ឍន៍សមត្ថភាពក្រៅប្រទេស និងលិខិតឆ្លងដែន**

-បន្តរៀបចំបែបបទដើម្បីបញ្ជូនមន្ត្រីទៅចូលរួមសកម្មភាពអភិវឌ្ឍន៍សមត្ថភាពនៅក្រៅប្រទេស

-បន្តសហការជាមួយដៃគូ ដើម្បីស្វែងរកការគាំទ្រ និងកិច្ចសហការសម្រាប់ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទ ដើម្បីស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការតាមការស្នើសុំពីមន្ត្រីរាជការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**៣.៣-ការងារផ្សព្វផ្សាយ និងព័ត៌មាន**

-បន្តធ្វើបច្ចុប្បន្នភាពនិងបញ្ចូលអត្ថបទក្នុងគេហទំព័រអគ្គនាយកដ្ឋានរដ្ឋបាល

-បន្តស្រាវជ្រាវ និងសរសេរអត្ថបទដើម្បីបញ្ចូលទៅក្នុងព្រឹត្តិបត្រ «វិមជ្ឈការ និងវិសហមជ្ឈការ» ក្រសួងមហាផ្ទៃលេខ ០៤។

**៤-ការងារគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ**

**៤.១-ការងារគាំទ្របច្ចេកទេស និងអន្តរាគមន៍**

**ដើម្បីគាំទ្រដល់ការបំពេញតួនាទីភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរដ្ឋបាលបន្តពិនិត្យលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេច និងបន្តអនុវត្តលើកិច្ចការមួយចំនួនដូចខាងក្រោម៖**

**-រដ្ឋបាលខេត្តបន្ទាយមានជ័យ** ករណីឈ្មោះ **អ៊ូ ប៊ុនណារិទ្ធ** ស្នើសុំធ្វើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុមួយកន្លែង ស្ថិតនៅភូមិអណ្តូងថ្មមាស សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

**-រដ្ឋបាលខេត្តតាកែវ** ករណីឈ្មោះ **ឥន្ទ គា, ឡុត ស្រីពៅ, គាំង ថា, តាំង សៀន, សុំ សុខលី, អៀម នាង, អ៊ូ ប៊ុណ្ណា, ហាក់ ហេង, ថាវ សុគន្ធ, អួន ថា, សែត ខុន** និងឈ្មោះ **ដួង សុខា** ស្នើសុំចេញប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋចំនួន ១២គ្រួសារ ស្ថិតនៅភូមិ២ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ។

**-រដ្ឋបាលខេត្តកែប ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី** ករណីស្នើសុំពិនិត្យសម្រេចលើការកំណត់និមិត្តសញ្ញារបស់រដ្ឋបាលខេត្តខេត្តកែប **ខេត្តមណ្ឌលគិរី** និងខេត្តរតនគិរី សម្រាប់ប្រើប្រាស់ជាផ្លូវការ។

**-រដ្ឋបាលខេត្តព្រះសីហនុ** ករណី៖

• ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លើកឡើងនូវកង្វល់អំពីបញ្ហាសិទ្ធិមនុស្សពាក់ព័ន្ធនឹងការបណ្តេញចេញប្រជាពលរដ្ឋចំនួន ១៣៤គ្រួសារ និងប្រជាពលរដ្ឋខ្មែរ-ឥស្លាមចំនួន ៥៩គ្រួសារ ស្ថិតនៅភូមិស្មាច់ដែង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

• ធ្វើសេចក្តីរាយការណ៍អំពីសំណើសុំអន្តរាគមន៍ដោះស្រាយឱ្យប្រជាពលរដ្ឋ និងអាជីវករចំនួន ៦២គូប បានអាស្រ័យផល និងអនុញ្ញាតបន្តអាជីវកម្មនៅទីតាំងដដែល ស្ថិតនៅឆ្នេរអូរត្រេះ ក្នុងភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

**-រដ្ឋបាលខេត្តឧត្តរមានជ័យ** ករណីតំណាងប្រជាពលរដ្ឋ ១៨គ្រួសារ ប្តឹងមន្ត្រីរដ្ឋបាលស្រុកអន្លង់វែង ដែលបានដឹកនាំកម្លាំងចម្រុះទៅហាមឃាត់ប្រជាពលរដ្ឋមិនឱ្យបង្កបង្កើនផលលើដីរបស់ខ្លួន ស្ថិតនៅភូមិលំទងចាស់ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

**-រដ្ឋបាលខេត្តកណ្តាល** ករណី៖

• ឈ្មោះ **មៀច សំរួល** ប្តឹងឈ្មោះ **និត ពៅ** និងប្តី (រ៉ា វុត្ថារ៉ា) ឈ្មោះ **វណ្ណ សុភាពមុន្នី** និងបក្ខពួកគ្រួសារជាម្ចាស់ដីឡូត៍មានទីតាំងស្ថិតនៅភូមិខ្នារ និងភូមិបឹងខ្នារ ឃុំទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល

• ឈ្មោះ **ភួន ភូម៉ូនីរតន៍** ស្នើសុំជួយអន្តរាគមន៍លើករណីដីទំហំ ២០ម x ៣០មចំនួន ០៣ឡូតិ៍ ប្លុកG១៦ (ឡូតិ៍លេខ១៨ លេខ២០ និងលេខ២១) លើទីតាំងក្បាលដីលេខ ០៨០១០៥០៥-០៦៨០ ដែលគាត់បានទិញពីក្រុមហ៊ុនលាន ហេង ត្រេឌីង(បូរីកាំងម៉េង)ស្ថិតនៅក្នុងភូមិព្រែកកំពឹស ឃុំជើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

**-រដ្ឋបាលខេត្តកំពង់ចាម** ករណីស្នើសុំការអនុញ្ញាតសម្រាប់សាងសង់អគារប៉ុស្តិ៍សុខភាពរបស់អង្គការស្ពានលើដីរបស់រដ្ឋបាលខេត្តកំពង់ចាម ស្ថិតនៅភូមិតាណោង សង្កាត់សំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម

**-រដ្ឋបាលខេត្តកោះកុង** ករណីតំណាងប្រជាពលរដ្ឋ **៧៤៣**គ្រួសារ ស្នើសុំជួយជំរុញ និងពន្លឿនការដោះស្រាយជម្លោះដីធ្លីរវាងប្រជាពលរដ្ឋជាមួយក្រុមហ៊ុន កោះកុងស៊ូហ្គើ និងកោះកុង ផ្លេនថេសិនអ៊ីនដាស់ស្ទ្រី ខមផេនី លីមិតធិត របស់លោកឧកញ៉ា លី យ៉ុងផាត់ នៅក្នុងទឹកដីស្រុកបូទុមសាគរ ស្រុកថ្មបាំង និងស្រុកស្រែអំបិល។

-បន្តរៀបចំ កែសម្រួលនូវប្រព័ន្ធរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត។

-បន្តរៀបចំបូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**៤.២-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ**

**អគ្គនាយកដ្ឋានរដ្ឋបាល បន្តពិនិត្យ និងលើកយោបល់ ជូនថ្នាក់ដឹកនាំក្រសួងពាក់ព័ន្ធនឹងការកែសម្រួលព្រំប្រទល់រដ្ឋបាល និងការបង្កើតភូមិ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម៖**

**-រដ្ឋបាលខេត្តបន្ទាយមានជ័យ** ករណីស្នើសុំបង្កើតភូមិថ្មីចំនួន ០២ ស្ថិតក្នុងឃុំណាំតៅ ស្រុកភ្នំស្រុក និងភូមិចំនួន ០៥ ស្ថិតក្នុងឃុំតាគង់ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

**-រដ្ឋបាលខេត្តតាកែវ** ករណីរដ្ឋបាលឃុំកំពង់រាប ឃុំព្រៃល្វា ស្នើសុំបំបែកភូមិ ចំនួន ០៣ ស្ថិតក្នុងឃុំកំពង់រាបនិងឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ។

**-រដ្ឋបាលខេត្តព្រៃវែង** ករណីស្នើសុំបំបែកភូមិចំនួន **០៤ភូមិ** ក្នុងនោះស្ថិតនៅក្នុងឃុំកំពង់ពពិលចំនួន **០១ភូមិ** និងឃុំកញ្ចំចំនួន **០៣ភូមិ** នៃស្រុកពារាំង ខេត្តព្រៃវែង។

**-រដ្ឋបាលខេត្តកំពត** ករណីស្នើសុំកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងក្រុងកំពត និងស្រុកទឹកឈូ។

**-រដ្ឋបាលខេត្តសៀមរាប ព្រះវិហារ ឧត្តរមានជ័យ និងខេត្តបាត់ដំបង** ករណីស្នើសុំកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងខេត្តសៀមរាប ជាមួយខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តបាត់ដំបង។

**-ខេត្តកំពង់ស្ពឺ** ករណីស្នើសុំបង្កើតភូមិថ្មីចំនួន ០១ ស្ថិតនៅឃុំវល្លិសរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

**៤.៣-ការងារផ្តល់គោរមងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ**

-បន្តតាមដាន ត្រួតពិនិត្យអំពីការអនុវត្តលិខិតលេខ ១៩៧៣ស.ជ.ណ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការពង្រឹងការគ្រប់គ្រង ការស្នើសុំគ្រឿងឥស្សរិយយសស្ថាបនាជាតិ និងគោរមងារជាឧកញ៉ាជូនសប្បុរសជនដែលមានស្នាដៃ និងគុណបំណាច់ក្នុងការជួយកសាងជាតិក្នុងព្រះរាជាណាចក្រកម្ពុជា។

-បន្តពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួង ករណីសំណើសុំគ្រឿងឥស្សរិយយសរបស់រដ្ឋបាលខេត្តកំពង់ចាម ។

### ៤.៤-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា

#### ៤.៤.១-កម្មវិធីគាំទ្រដោយអង្គការ UNICEF

-បន្តរៀបចំសេចក្តីព្រាងសៀវភៅណែនាំ ស្តីពីកម្មវិធីពានរង្វាន់សម្រាប់ការអនុវត្តសេវាសង្គម នៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តរៀបចំសំណើសុំថវិកាអនុវត្តគម្រោងត្រីមាសទី២ ឆ្នាំ២០២០

-បន្តរៀបចំប្រព័ន្ធទិន្នន័យអនឡាញ (Data Base of SNAs) របស់រដ្ឋបាលរាជធានី ខេត្ត។

#### ៤.៤.២-គម្រោងសាងសង់អគាររដ្ឋបាល អាគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ DCOCP

-បន្តតាមដាន និងសម្របសម្រួលទាក់ទងនឹងសំណើសុំថវិកាបន្ថែមទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរក្សាការសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់តាមចំនួនដែលបានគ្រោងទុក

-បន្តចុះពិនិត្យ និងតាមដានដំណើរការសាងសង់អគារសាលាស្រុក និងឃុំ សង្កាត់ដំណាក់កាលទី១ ទី២ និងទី៣។

### ៤.៥-ការងាររដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់

-បន្តសិក្សា និងរៀបចំប្រព័ន្ធតាមដានដំណើរការសិក្សាផលប៉ះពាល់បរិស្ថាន និងសង្គម

-បន្តធ្វើបច្ចុប្បន្នភាពដំណើរការកសាងកម្មវិធីវិនិយោគក្រុង ស្រុក ឃុំ សង្កាត់ឆ្នាំ២០២០-២០២២ បន្តធ្វើបច្ចុប្បន្នភាពផែនការអភិវឌ្ឍប្រាំឆ្នាំ២០២០-២០២៤របស់រដ្ឋបាលក្រុង ស្រុក

-បន្តធ្វើបច្ចុប្បន្នភាព និងទីតាំងអគាររដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ប្រចាំត្រីមាសទី១ឆ្នាំ២០២០

-បន្តគាំទ្រ និងតាមដានដំណើរការសិក្សារៀបចំគម្រោងក្រុង ស្រុក ឃុំ សង្កាត់ និងតាមដានវាយតម្លៃគម្រោង

-បន្តគាំទ្រ និងតាមដានដំណើរការលទ្ធកម្ម និងគ្រប់គ្រងកិច្ចសន្យា

-ចុះតាមដានការអនុវត្តថវិកាក្រុង ស្រុក ឃុំ សង្កាត់ឆ្នាំ២០១៩ និងការរៀបចំថវិកាក្រុង ស្រុក ឃុំ សង្កាត់ឆ្នាំ២០២០

-បន្តតាមដានការបិទបញ្ជីថវិកាឆ្នាំ២០១៩ និងការរៀបចំថវិការបស់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់។

### ៤.៦-ការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-រៀបចំកិច្ចប្រជុំពិនិត្យលើឯកសារទស្សនទាន និងបញ្ជីសំណួរ សម្រាប់ចុះសិក្សាការរៀបចំការិយាល័យច្រកចេញចូលតែមួយ ការកែសម្រួលតួនាទី ភារកិច្ច និងនីតិវិធីនៃការផ្តល់សេវារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

-បន្តសហការជាមួយធនាគារពិភពលោក ដើម្បីចុះសិក្សា និងប្រមូលព័ត៌មានអំពីស្ថានភាពនៃការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន និងការគ្រប់គ្រងទីលានចាក់សំរាមនៅក្រុង ស្រុកគោលដៅមួយចំនួនបន្ថែមទៀត

-បន្តសហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធផ្សេងៗ និងលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងដំណើរការរៀបចំផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

-ផ្សព្វផ្សាយអនុក្រឹត្យ ស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-រៀបចំដាក់ឱ្យដំណើរការសាកល្បងកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូល តែមួយរាជធានី ខេត្តចំនួន៥

-ចុះសិក្សាអំពីជម្រើសនៃការរៀបចំការិយាល័យច្រកចេញចូលតែមួយ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ

-រៀបចំវគ្គតម្រង់ទិស ស្តីពីតួនាទី ភារកិច្ច និងនីតិវិធីសម្រុះសម្រួលដោះស្រាយបណ្តឹងដល់ការិយាល័យប្រជាពលរដ្ឋខេត្តតាកែវ

-រៀបចំកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីនីតិវិធីបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌដល់អ្នកពាក់ព័ន្ធដើម្បីជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋស្រុក៨៨គោលដៅ។

## ៥-ការងារសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា

ដើម្បីលើកកម្ពស់កិច្ចសហការជាមួយក្រសួង ស្ថាប័ននានា អគ្គនាយកដ្ឋានរដ្ឋបាលបន្តពិនិត្យ និងលើកយោបល់លើករណីដូចខាងក្រោម៖

-ស្ថានីយ៍ទូរទស្សន៍-វិទ្យុអាស៊ីអាគ្នេយ៍ ករណីស្នើសុំការអនុញ្ញាតទទួលស្គាល់លិខិតឧទ្ទេសនាមសម្រាប់ក្រុមការងារពិសេសនៃផ្នែកផលិតកម្មវិធីរបស់ស្ថានីយ៍ទូរទស្សន៍-វិទ្យុអាស៊ីអាគ្នេយ៍ មានលទ្ធភាពដើម្បីថតសកម្មភាព រូបភាព យកព័ត៌មាន និងផលិតកម្មវិធីផ្សេងៗនៅតាមរាជធានី ខេត្ត។

-វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ករណីស្នើសុំអនុញ្ញាតចុះធ្វើការអង្កេតសម្រាប់ការសិក្សាស្តីពី"ការវិភាគទស្សនយេនឌ័រលើភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនិងអាហារូបត្ថម្ភៈ ប្រទេសកម្ពុជា និងប្រទេសឥណ្ឌាភាគខាងត្បូង"។

-ក្រុមហ៊ុន ហាវ៉ស់ប៊ែហ្វូត ឯ.ក ករណីស្នើសុំចុះស្ទង់មតិប្រជាពលរដ្ឋអំពីការយល់ឃើញទៅលើស្ថានភាពដែលពាក់ព័ន្ធនឹងសហគមន៍ក្នុងប្រទេសកម្ពុជា ដែលនឹងត្រូវចុះតាមរាជធានីភ្នំពេញ និងតាមខេត្ត។

**៦-ការងារតាមវិស័យផ្សេងៗ**

**៦.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន និងប័ណ្ណព្រំដែន**

-បន្តសម្របសម្រួលរៀបចំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងដើម្បីសិក្សា និងដោះស្រាយបញ្ហាបាក់ច្រាំងទន្លេបាសាក់-ទន្លេហ្វិរ និងព្រែកជ្រៃធំ-ព្រែកប៊ិញយី នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម។

-ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំឱ្យបានជ្រាបអំពីលទ្ធផលនៃការចូលរួមកិច្ចប្រជុំអន្តរក្រសួងចង្អៀតដើម្បីពិនិត្យ និងពិភាក្សាសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទស្នើសុំដាក់បញ្ចូលច្រកទ្វារអូរបីជាន់ ស្ថិតនៅស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ទៅជាច្រកទ្វារតំបន់ព្រំដែនស្របតាមអនុក្រឹត្យលេខ ៦៤អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ របស់រាជរដ្ឋាភិបាល។

-ពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំពិនិត្យសម្រេច អំពីលទ្ធផលនៃការចូលរួមកិច្ចប្រជុំ ពិភាក្សាអំពីការសាងសង់ស្ពានឆ្លងកាត់អូរធម្មជាតិនៅច្រកទ្វារព្រំដែនព្រំ (ខេត្តប៉ៃលិន)-បានផាកាដ (ច័ន្ទបុរី) កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ នៅខេត្តច័ន្ទបុរី នៃព្រះរាជាណាចក្រថៃ។

-បន្តតាមដាន និងគាំទ្រដល់រដ្ឋបាលខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវដល់ដំណើរការផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋខ្មែរនៅតាមបណ្តាខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវ ប្រើប្រាស់ព្រមទាំងបន្តតាមដាន និងសិក្សាលទ្ធភាពក្នុងការផ្តល់សេវាប័ណ្ណព្រំដែននៅក្រុង ស្រុក និងច្រកទ្វារព្រំដែននៃបណ្តាខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវ។

-បន្តតាមដាន និងសិក្សាលទ្ធភាពក្នុងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យប័ណ្ណព្រំដែនកម្ពុជា/ថៃឱ្យមានភាពប្រសើរឡើង និងប្រសិទ្ធភាពខ្ពស់។

**៦.២-ការងារចងសម្ព័ន្ធមេត្រីភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តពិនិត្យលើកយោបល់លើសំណើរបស់រដ្ឋបាលខេត្តសៀមរាបករណី៖

• សំណើសុំគោលការណ៍អនុញ្ញាតឱ្យរដ្ឋបាលក្រុងសៀមរាប ខេត្តសៀមរាប ចុះហត្ថលេខាលើអនុស្សរណៈកិច្ចព្រមព្រៀងសម្ព័ន្ធមេត្រីភាពជាមួយក្រុងតាថុង ខេត្តសានស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន។

• សំណើសុំគោលការណ៍អនុញ្ញាតរដ្ឋបាលខេត្តសៀមរាប ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីការបង្កើតសម្ព័ន្ធមេត្រីភាពជាមួយក្រុងស៊ីអាន ខេត្តសានស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន។

- បន្តសម្របសម្រួលរៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកទី៧ ដែលភាគីថៃទទួលធ្វើជាម្ចាស់ផ្ទះក្នុងឆ្នាំ២០២០។

- បន្តសម្របសម្រួលលើការងាររៀបចំកិច្ចប្រជុំលើកទី២ របស់ក្រុមការងារចម្រុះ ស្តីពីច្រកទ្វារព្រំដែនគោកកម្ពុជា-វៀតណាម។

- បន្តសម្របសម្រួលលើការងាររៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាមលើកទី១១។

- បន្តសម្របសម្រួល លើករណីស្នើសុំរបាយការណ៍លទ្ធផលកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម។

### ៦.៣-ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យ

អគ្គនាយកដ្ឋានរដ្ឋបាល បន្តពិនិត្យនិងលើកយោបល់ ចំពោះសំណើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម៖

-រដ្ឋបាលរាជធានី ខេត្ត ករណីសំណើផ្តល់អនុលោមភាពគម្រោងអភិវឌ្ឍន៍ឆ្នាំ២០១៩-២០២០ និង ផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ២០២០-២០២៤របស់រដ្ឋបាលរាជធានី ខេត្ត។

-រដ្ឋបាលខេត្តមណ្ឌលគិរី ករណីស្នើសុំគោលការណ៍រៀបចំតំបន់រដ្ឋបាលស្រុកអូររាំងថ្មី ដោយកាត់ដីទំហំ ២១៧,៨៣២ ហិកតាស្ថិតនៅក្នុងភូមិពូរ៉ាង ឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគិរី។

-រដ្ឋបាលខេត្តកំពង់ចាម ករណីសំណើសុំគោលការណ៍ជម្រះចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់រដ្ឋបាលសង្កាត់កំពង់ចាម (អតីតសាលាឃុំកំពង់ចាម) ក្រុងកំពង់ចាម ខេត្តកំពង់ចាម។

-បន្តចាត់ចែងតាមបែបបទនីតិវិធី ករណីរាជរដ្ឋាភិបាលបានឯកភាពលើសំណើសុំកាត់ដីទំហំ៩ម៉ែត្រ x ២០ម៉ែត្រ ស្មើនឹង ១៨០ម៉ែត្រការ៉េ ចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ការិយាល័យកសិកម្មស្រុកកញ្ជៀច នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ៦.៤-ការងារកិច្ចការសមាគម និងគណបក្សនយោបាយ

#### ៦.៤.១-ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តលើកយោបល់អំពីការសុំចុះឈ្មោះ សុំបើកទីស្នាក់ការសាខា សុំទទួលស្គាល់ប្រធាន និងសមាសភាពថ្មី នៃរចនាសម្ព័ន្ធ សុំប្តូរទីស្នាក់ការកណ្តាល សុំប្តូរឈ្មោះ សុំធ្វើវិសោធនកម្មលក្ខន្តិកៈ សុំលុបឈ្មោះ ការផ្អាកសកម្មភាព សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសំណើផ្សេងៗដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេច

-បន្តលើកយោបល់អំពីការសុំតម្កល់សំណុំឯកសារ អំពីការផ្លាស់ប្តូរសមាសភាពរចនាសម្ព័ន្ធ និងការធ្វើវិសោធនកម្មលក្ខន្តិកៈរបស់សហគមន៍ជនជាតិដើមភាគតិច

-បន្តគាំទ្រកិច្ចដំណើរការរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តធ្វើបច្ចុប្បន្នភាព និងបូកសរុបរបាយការណ៍សកម្មភាព និងការផ្តល់លេខគណនីរបស់សមាគម និង អង្គការមិនមែនរដ្ឋាភិបាល

-បន្តតាមដាន ប្រមូលព័ត៌មានពីគ្រប់បណ្តាញព័ត៌មានសង្គមពាក់ព័ន្ធនឹងការធ្វើសកម្មភាពសមាគម និង អង្គការមិនមែនរដ្ឋាភិបាល

-បន្តតាមដាន ត្រួតពិនិត្យ និងពង្រឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងលក្ខន្តិកៈរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តចូលរួមកិច្ចប្រជុំជាមួយក្រុមការងារវាយតម្លៃអញ្ញមញ្ញ ស្តីពីការប្រឆាំងការសម្អាតប្រាក់និង ហិរញ្ញប្បទានភេរវកម្មនិងចូលរួមប្រជុំជាមួយតំណាងក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់(APG)

-បន្តចូលរួមកិច្ចប្រជុំជាមួយក្រុមការងារត្រួតពិនិត្យរួមគ្នានៃប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិកាសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (ICRP-JG) នៃក្រុមការងារហិរញ្ញវត្ថុ (FATF)

-ត្រៀមរៀបចំកិច្ចប្រជុំពិនិត្យពិភាក្សាសំណើ និងអនុសាសន៍របស់អង្គការសង្គមស៊ីវិលក្នុងការធ្វើ វិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

#### ៦.៤.២-ការងារគណបក្សនយោបាយ

-បន្តពិនិត្យ លើកយោបល់ អំពីការសុំបង្កើត ឬការសុំចុះបញ្ជីនិងសំណើនានារបស់គណបក្សនយោបាយ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេច

-បន្តពិនិត្យ លើកយោបល់ នូវរាល់សំណើពាក់ព័ន្ធនិងការផ្លាស់ប្តូរ ឬការប្រែប្រួលនានារបស់គណបក្សនយោបាយ

-រៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះគណបក្សនយោបាយដែលបានបង្កើត បានចុះបញ្ជី និងត្រូវបានលុបឈ្មោះ

-បន្តតាមដានពិនិត្យបូកសរុបប្រមូលព័ត៌មាន ពីគ្រប់បណ្តាញព័ត៌មានសង្គម និងរបាយការណ៍របស់រដ្ឋបាលរាជធានី ខេត្ត ចំពោះគណបក្សនយោបាយ ដែលបានធ្វើសកម្មភាពផ្ទុយពីលក្ខន្តិកៈ ច្បាប់ស្តីពីគណបក្សនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាធរមាននានា

-បន្តពិនិត្យ និងពិភាក្សាអំពីការធ្វើវិសោធកម្មប្រកាសរួមលេខ ០០៧សហវ.ហ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីអាករចុះបញ្ជីគណបក្សនយោបាយ រវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ពិនិត្យ និងដោះស្រាយពាក្យបណ្តឹង ឬសំណើនានារបស់គណបក្សនយោបាយ

-រៀបចំបោះពុម្ពសៀវភៅច្បាប់ស្តីពីគណបក្សនយោបាយចំនួន ៥.០០០ក្បាល ដើម្បីធ្វើការផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធនានា៕

អគ្គនាយក

**ប្រាក់ សំអឿន**

<u>ចម្លងជូន៖</u>

*-ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ*
*(ជូនជ្រាបជាសេចក្តីរាយការណ៍)*
*-អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ*
*-អគ្គស្នងការដ្ឋាននគរបាលជាតិ*
*-អគ្គនាយកដ្ឋានរតនាគារ និងហិរញ្ញវត្ថុ*
*-អគ្គាធិការដ្ឋាន*
*-អគ្គនាយកដ្ឋានពន្ធនាគារ*
*-គ្រប់នាយកដ្ឋានចំណុះអ.រ.ប*
*"ដើម្បីជូនជ្រាប"*
*-ឯកសារ-កាលប្បវត្តិ*